ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY


# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ភាពខុសគ្នារវាងអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេសនៃអគ្គនាយកដ្ឋានពន្ធដារ

## THE DIFFERENCE BETWEEN THE TAX FOR PUBLIC LIGHTING AND THE SPECIAL TAX OF THE GENERAL DEPARTMENT OF TAXATION

ជំនាញ គណនេយ្យ


រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ភាពខុសគ្នារវាងអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេសនៃអគ្គនាយកដ្ឋានពន្ធដារ

## THE DIFFERENCE BETWEEN THE TAX FOR PUBLIC LIGHTING AND THE SPECIAL TAX OF THE GENERAL DEPARTMENT OF TAXATION

**គ្រូណែនាំៈ លីម គន្ធា**

**ជំនាញ គណនេយ្យ**

**រាជធានីភ្នំពេញ-ឆ្នាំ២០២៥**

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទ៖ ភាពខុសគ្នារវាងអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេស**
**នៃអគ្គនាយកដ្ឋានពន្ធដារ**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

លីម គន្ធា

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃនិងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យ វ៉ាន់ដា អស់រយៈពេល ៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ ជាពិសេស ក្រុមរបស់យើងខ្ញុំយល់យ៉ាងច្បាស់ថា ជំនាញគណនេយ្យជាជំនាញមួយ ដែលមានសារៈសំខាន់សម្រាប់ទីផ្សារ បច្ចុប្បន្នក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវបានអនុវត្តកិច្ចការគណនេយ្យដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យ វ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗ ដែលពាក់ព័ន្ធនឹងការងារគណនេយ្យតាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់នៅក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្តការងារគណនេយ្យ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយ ស្តីពី "**ភាពខុសគ្នារវាងអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេសនៃអគ្គនាយកដ្ឋានពន្ធដារ**" យកមកធ្វើការសិក្សាស្រាវជ្រាវ ដើម្បីចងក្រងក្នុងគោលបំណងឱ្យអ្នកសិក្សាស្រាវជ្រាវទាំងអស់ ស្វែងយល់ពីអត្ថន័យកាន់តែស៊ីជម្រៅអំពីការរៀបចំសារណា និងដំណើរនៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។ ក្រុមយើងខ្ញុំសង្ឃឹមថា ការរៀបចំសារណានេះ នឹងបានចូលរួមចំណែកនៅក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀត ដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



**មាស ឆារ៉ា**
ID: B22/1487



**យឹម ស្រីនិច**
ID: B22/361



**ពេជ្រ ស្រីនាគ**
ID: B22/1297



**យ៉ុខ ណៃអ៊ី**
ID: B22/366

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាន់ទី២២ ជំនាញគណនេយ្យនៃសាកលវិទ្យាល័យវ៉ាន់ដា ត្រូវនឹងឆ្នាំសិក្សា ២០២៤-២០២៥។

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលមានគុណគ្មានអ្វីអាចមកប្រៀបផ្ទឹមបានដែលលោកបានផ្តល់កំណើត និងបីបាច់ថែរក្សាតាំងពីតូចរហូតដល់ធំដឹងក្តី ព្រមទាំងទូន្មានប្រៀនប្រដៅ អប់រំយើងខ្ញុំឱ្យរស់នៅប្រកបទៅដោយសីលធម៌ និងសុជីវធម៌ ។ លើសពីនេះទៀតលោកបាន ទំនុកបម្រុង គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ ។ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់ខ្ញុំបាទ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌិតសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក ។

ក្រុមយើងខ្ញុំ សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ ។

សូមគោរពថ្លែងអំណរគុណចំពោះគ្រូណែនាំ **លីម គន្ធា** ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតដល់ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

## អំណះអំណាង

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២៖ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទស្តីអំពី " **ភាពខុសគ្នារវាងអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេសនៃអគ្គនាយកដ្ឋានពន្ធដារ** " នេះគឺពិតជាស្នាដៃមួយរបស់ក្រុមខ្ញុំបាទ នាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធ នឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ ។ ទិន្នន័យ និងលទ្ធផលដែលទាក់ទងទៅនឹងការស្រាវជ្រាវ ដែលបានលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ ។

ថ្ងៃពុធ ៨កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥
**ហត្ថលេខាតំណាងក្រុម**

មាស ធាវ៉ា

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

អាករបំភ្លឺសាធារណៈ មានន័យថាអាករមួយប្រភេទដែលបង្កើតឡើងដើម្បីជាប្រយោជន៍ដល់ថវិកាថ្នាក់ក្រោមសម្រាប់បំភ្លឺផ្លូវសាធារណៈទូទាំងប្រទេស ។ អាករប្រភេទនេះត្រូវបានកំណត់លើគ្រប់ដំណាក់កាលនៃការផ្គត់ផ្គង់សុរាមេរ័យ (គ្រឿងស្រវឹង) និងបារីបន្ទាប់ពីបាននាំចូល ឬផលិតផលជាប់អាករក្នុងព្រះរាជាណាចក្រកម្ពុជា ។ ចំពោះការប្រមូលពន្ធអាករបំភ្លឺសារធារណៈ គឺជាការផ្តល់ព័ត៌មាន និងចម្រាញ់ការដើម្បីឱ្យប្រជាជន ឬអ្នកជំនាញបានយល់ពីមូលហេតុ និងអត្ថប្រយោជន៍នៃការបង់ពន្ធ ។ វាជាការបង្ហាញពីការប្រើប្រាស់ប្រាក់ពន្ធដោយត្រឹមត្រូវ ច្បាស់លាស់ដើម្បីទទួលបានការយល់ព្រម និងការទទួលខុសត្រូវពីប្រជាជន ។

អាករពិសេស គឺយកទៅលើទំនិញ និងសេវាមួយចំនួនត្រូវបានកំណត់លើទំនិញនិងសេវាមួយចំនួន ។ ទំនិញដែលជាប់អាករនេះរួមមានស្រា(៣៤%) ស្រាបៀរ(៣០%) និងបារី(20%)។ ចំពោះសេវាដែលជាប់អាករនេះមានសេវាលំហែកម្សាន្ត សេវាដឹកអ្នកដំណើរតាមផ្លូវអាកាស(១០%) និងសេវាទូរស័ព្ទ(៣%) ។ ហើយទំនិញផលិតក្នុងស្រុកមូលដ្ឋានសម្រាប់គិតអាករពិសេសត្រូវកំណត់ស្មើ នឹង ៩០ភាគរយនៃតម្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាក្នុងវិក្កយបត្រឱ្យទៅអតិថិជនដោយមិនរួមបញ្ចូលអាករលើតម្លៃបន្ថែមអាករសម្រាប់អាករបំភ្លឺសាធារណៈ និងអាករពិសេសខ្លួនឯង ។

គោលបំណងនៃអាករបំភ្លឺសាធារណៈ និងអាករពិសេសគឺដើម្បីធ្វើឱ្យប្រជាជនមានការយល់ដឹង និងចេះពីការចំណាយសាធារណៈ និងច្បាប់ពាក់ព័ន្ធនានា។ ការបំភ្លឺនេះ អាចជួយឱ្យបង្កើនការទទួលខុសត្រូវពីរាជរដ្ឋាភិបាល និងការផ្តល់អាហារូបករណ៍នៅក្នុងសង្គម។ បន្ថែមពីនេះ វានៅតែអាចជួយឱ្យបញ្ហាសាធារណៈត្រូវបានដោះស្រាយ ដោយមានការយល់ដឹងច្បាស់ពីមនុស្សក្នុងសង្គមទាំងអស់ ។

សរុបសេចក្តីមក ការប្រមូលអាករបំភ្លឺសាធារណៈ និងអាករពិសេសកន្លងមកអាចសន្និដ្ឋានបានថាដំណើរការនៃការប្រមូលអាករទាំងពីរ ជាការប្រមូលពន្ធមួយប្រភេទដែលប្រមូលប្រាក់ចំណូលបានខ្ពស់មានដូចជាការកើនឡើងនៃចំនួនអ្នកជាប់ពន្ធពីមួយឆ្នាំទៅមួយឆ្នាំ មានការកើនឡើងពីបុគ្គលជាប់អាករតាមរយៈការផ្គត់ផ្គង់សេវា និងទំនិញ(បារី និងសុរាមេរ័យ)។ ម្យ៉ាងវិញទៀត ដំណើរការនៃការប្រមូលអាករទាំងនេះក៏ជាចលកមួយជួយជំរុញដល់ការអភិវឌ្ឍប្រទេសជាតិ និងបានចូលរួមដោះស្រាយបញ្ហាជាតិផងដែរ តាមរយៈទឹកប្រាក់ដែលប្រមូលបានត្រូវយកទៅ កសាងសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពានអាកាស ប្រាក់ខែមន្ត្រីរាជការ និងហេដ្ឋារចនាសម្ពន្ធ័នានា ។

# មាតិកា

ទំព័រ


អារម្ភកថា ........ i
រចនាសម្ព័ន្ធ ........ ii
សេចក្តីថ្លែងអំណរគុណ ........ iii
អំណះអំណាង ........ iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v
មាតិកា ........ vi


## ជំពូកទី១
## សេចក្តីផ្តើម


១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៤.១ ទំហំដែនកំណត់ ........ ២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២
១.៥.១ ការប្រមូលទិន្ន័យដំបូង ........ ២
១.៥.២ ការប្រមូលទិន្ន័យបន្ទាប់ ........ ២
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣


## ជំពូកទី២
## ភាពខុសគ្នារវាងអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេសនៃអគ្គនាយកដ្ឋានពន្ធដារ


២.១ លក្ខណៈទូទៅនៃអាករបំភ្លឺសាធារណៈ ........ ៥
២.១.១ និយមន័យអាករ ........ ៥
២.១.២ ប្រវត្តិនៃអាករ ........ ៥
២.១.៣ ទ្រឹស្តីនៃអាករ ........ ៦
២.២ យុទ្ធសាស្ត្រអាករពិសេស ........ ៨
២.២.១ និយមន័យអាករពិសេស ........ ៨
២.២.២ ប្រវត្តិនៃអាករពិសេស ........ ៩
២.២.៣ ទ្រឹស្តីអាករពិសេស ........ ១០
២.៣ នីតិវិធីនៃការប្រមូលពន្ធលើអាករសម្រាប់បំភ្លឺសាធារណៈអាករពិសេស ........ ១១

២.៣.១ និយមន័យនៃនីតិ ........ ១១
២.៣.២ ប្រវត្តិនៃនីតិ ........ ១១
២.៣.៣ ទ្រឹស្តីនៃនីតិ ........ ១២

## ជំពូកទី៣

## ភាពខុសគ្នារវាងអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេសនៃអគ្គនាយកដ្ឋានពន្ធដារ

៣.១ស្ថានភាពទូទៅនៃអាករបំភ្លឺសាធារណៈ ........ ១៣
៣.១.១ ប្រវត្តិរបស់អាករបំភ្លឺសាធារណៈ ........ ១៣
៣.១.២ បេសកកម្ម ទស្សនៈវិស័យរបស់អាករសម្រាប់បំភ្លសាធារណៈ ........ ១៤
៣.១.៣ បេសកកម្ម ទស្សនៈវិស័យរបស់អាករពិសេស ........ ១៤
៣.១.៤ រចនាសម្ព័ន្ធគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ ........ ១៥
៣.២ ភាពខុសគ្នារវាងអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេសនៃអគ្គនាយកដ្ឋានពន្ធដារ ........ ១៦
៣.២.១ គោលបំណងនៃអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេស ........ ១៨
៣.២.២ បុគ្គលជាប់អាករ ........ ១៩
៣.៣ នីតិវិធីនៃការប្រមូលពន្ធលើអាករសម្រាប់បំភ្លឺសាធារណៈអាករពិសេស ........ ២២
៣.៣.១មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេស ........ ២២
៣.៣.២វិធីសាស្រ្តនៃការប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេស ........ ២២
៣.៣.៣ទំនិញដែលលើលែងពន្ធ និងអាករ ........ ២៧

## ជំពូកទី៤

## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ........ ៣០
៤.២ ការវិភាគលើចំណុចខ្សោយ ........ ៣០

## ជំពូកទី៥

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ........ ៣១
៥.២ ការផ្តល់អនុសាសន៍ ........ ៣១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

សព្វថ្ងៃនេះនៅលើបណ្តាប្រទេសគ្រប់សកលលោកទាំងអស់កំពុងតែមានការអភិវឌ្ឍនយ៉ាងខ្លាំងទៅលើគ្រប់វិស័យទាំងអស់ រួមទាំងប្រទេសកម្ពុជាយើងក៏មានការរីកចម្រើន និងអភិវឌ្ឍនយ៉ាងខ្លាំងក្រោយពីបានឆ្លងកាត់សង្គ្រាមអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ មួយវិញទៀត ចំពោះការអភិវឌ្ឍននោះប្រទេសកម្ពុជាយើងក៏ទទួលបានប្រភពចំណូលផងដែរ ដែលបានមកពីវិស័យជាច្រើនដូចជាវិស័យ កសិកម្ម ទេសចរណ៍ និងវិស័យឧស្សាហកម្ម ដែលជាប្រភពចំណូលចម្បង ដែលធ្វើអោយប្រទេសកម្ពុជាមានការរីកចម្រើន ។ ជាមួយគ្នានេះដែរកម្ពុជាក៏រីកចម្រើនខ្លាំងទៅលើគោលនយោបាយសារពើពន្ធផងដែរ ។

តួយ៉ាងការប្រមូលពន្ធទាំងនេះ វាមានពន្ធជាច្រើនរួមមាន ពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ពន្ធអប្បរមា ពន្ធលើប្រាក់បៀវត្ស អាករលើតម្លៃបន្ថែម អាករពិសេស ពន្ធលើឈ្នួលផ្ទះ ពន្ធលើផលរបរពន្ធប៉ាតង់ អាករលើការស្នាក់ ពន្ធប្រថាប់ត្រា ពន្ធលើដីធ្លីមិនបានប្រើប្រាស់ អាករបំភ្លឺសាធារណៈ និងពន្ធលើអចលនទ្រព្យ។ ជាក់ស្តែង គឺយើងលើកយកពីគោលនយោបាយដែលទាក់ទងនឹងពន្ធ អាករបំភ្លឺសាធារណៈ និងអាករពិសេស គឺជាគោលនយោបាយមួយដែលត្រូវបានបង្កើតឡើង ហើយគ្រប់គ្រងដោយអគ្គនាយកដ្ឋានពន្ធដារក្នុងគោលបំណងតាមដានទៅលើការផ្គត់ផ្គង់គ្រប់ដំណាក់កាលនូវ សុរាមេរ័យ និងទៅលើបារី បន្ទាប់ពីនាំចូល ឬការផលិតក្នុងព្រះរាជាណាចក្រកម្ពុជា។ មួយផ្នែកទៀតទៅលើទំនិញ សេវាមួយចំនួន ក្នុងគោលបំណងដើម្បីទប់ស្កាត់នូវផលវិបាកដែលកើតឡើងទៅលើផលិតផល និងមុខទំនិញខាងលើនោះហើយការប្រមូលពន្ធទាំងនោះ គឺជម្រុញឱ្យមានកំណើនសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព និងសមធម៌។ មួយវិញទៀតពន្ធដារ ក៏មានតួនាទីសំខាន់ក្នុងការជួយបង្កើនថវិកាជាតិ សម្រាប់ធានានៅសេចក្តីត្រូវការចំណាយដែលកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំផងដែរ។ ការប្រមូលពន្ធ គឺជាការងារចម្បងដែលអ្នកជាប់ពន្ធក៏ត្រូវយល់ដឹងពីសារៈសំខាន់នៃពន្ធដារ និងច្បាប់របស់ពន្ធដារដូច្នេះ គ្រប់អ្នកជាប់ពន្ធទាំងអស់ត្រូវបង់ពន្ធជូនរដ្ឋដោយស្មោះត្រង់ ទើបរដ្ឋទទួលចំណូលដោយពេញលេញ និងប្រកបដោយភាពរីកចម្រើនទៅលើវិស័យពន្ធដារ ម្យ៉ាងវិញទៀតវិស័យពន្ធជាវិស័យមួយដែលបានជួយលើកស្ទួយកំណើនសេដ្ឋកិច្ចជាតិដ៏ធំមួយដែរ ពីព្រោះគ្រប់ការប្រមូលពន្ធទាំងអស់ដែលបានពីអ្នកជាប់ពន្ធ គឺរដ្ឋបានយកថវិការទាំងនោះទៅជួយសង្គមជាតិបានជាច្រើនផ្នែកដូចជា ផ្នែកក្រសួងអប់រំ ផ្នែកសុខាភិបាល និងផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គមជាតិដូចជា ផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យជាដើម ។

ដោយផ្អែកទៅលើហេតុផលខាងលើនេះ ហើយទើបក្រុមរបស់នាងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកនូវប្រធានបទ ***"ភាពខុសគ្នារវាងអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេសនៃអគ្គនាយកដ្ឋានពន្ធដារ"*** ដែលស្ថិតនៅក្នុងប្រភេទអាករពីរ ក្នុងចំណោមអាករទាំងអស់នៅកម្ពុជាយកមកសិក្សាស្រាវជ្រាវ ដើម្បីរៀបចំជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និងទុកសម្រាប់និស្សិតប្អូនៗជំនាន់ក្រោយធ្វើការស្រាវជ្រាវ ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្ននេះយើងឃើញថា ពន្ធដារដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកបង្កើនថវិកាជាតិ និង ចំណាយសាធារណៈដែលកើតឡើងពីមួយឆ្នាំទៅមួយឆ្នាំ ។ ដើម្បីជួយសម្រួលដល់បន្ទុកលើចំណាយទាំងអស់រដ្ឋាភិបាលបានបង្កើតពន្ធច្រើនប្រភេទដែលមានលក្ខណៈខុសៗគ្នាទៅតាមប្រភេទពន្ធនីមួយៗ ហេតុដូចនេះហើយទើបក្រុមនាងខ្ញុំបានលើកយកនូវសំណួរដូចខាងក្រោម៖

១. តើភាពខុសគ្នារវាងអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេសមានអ្វីខ្លះ?

២. តើនិតិវិធីនៃការប្រមូលពន្ធបំភ្លឺសាធារណៈ និងអាករពិសេសមានអ្វីខ្លះ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះគឺចង់បង្ហាញពីយន្តការនៃការគណនាអាករបំភ្លឺសាធារណៈ និងអាករពិសេសឱ្យអ្នកជាប់ពន្ធទាំងអស់យល់ដឹងច្បាស់អំពីកាតព្វកិច្ចរបស់ខ្លួនក្នុងការប្រកាសពន្ធប្រចាំខែ និងដើម្បីជាគុណប្រយោជន៍ ថវិកា សម្រាប់ថ្នាក់ជាតិ ដោយផ្តោតទៅលើ ៖

- យល់ដឹងពីភាពខុសគ្នារវាងអាករបំភ្លឺសាធារណៈ និងអាករពិសេស
- យល់ដឹងពីនិតិវិធីនៃការប្រមូលពន្ធបំភ្លឺសាធារណៈ និងអាករពិសេស
- យល់ដឹងពីពាក្យគន្លឹះដែលទាក់ទង និងអាករបំភ្លឺសាធារណៈ និងអាករពិសេស
- យល់ដឹងអំពីច្បាប់ជាច្រើនទាក់ទង និងអាករបំភ្លឺសាធារណៈ និងអាករពិសេស

## ១.៤ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំនិងដែនកំណត់

ការសិក្សាស្រាវជ្រាវនេះ គឺយើងសិក្សាទៅលើ **ភាពខុសគ្នារវាងអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេសនៃអគ្គនាយកដ្ឋានពន្ធដារ** ដែលមានទីតាំងនៅអាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០) និងម៉ៅសេទុង (២៤៥), Phnom Penh, Cambodia ។ ប្រសិនបើយើងលើកយកចំណុចដែលទាក់ទងទៅលើទំហំ និងដែនកំណត់នោះទូលំទូលាយហើយក៏មានច្រើនប្រភេទដែរ។ ដូចនេះហើយ ទើបតម្រូវយកប្រភេទពន្ធមួយយកមកសិក្សាស្រាវជ្រាវឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតដើម្បីឱ្យម្ចាស់ក្រុមហ៊ុន និងម្ចាស់អាជីវករដឹងថាខ្លួនជាប់ពន្ធនៅពេលណា ។

### ១.៤.២ វិសាលភាព

ក្នុងការស្រាវជ្រាវនេះផងដែល គ្របដណ្តប់តែទៅលើការអនុវត្តស្តីពី "**ភាពខុសគ្នារវាងអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេសនៃអគ្គនាយកដ្ឋានពន្ធដារ** " សម្រាប់ឆ្នាំ២០២៣តែប៉ុណ្ណោះ ។

## ១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានរៀបចំផែនការ និងប្រើប្រាស់វិធីសាស្រ្តដើម្បីប្រមូលទិន្នន័យ វិភាគ និងបកស្រាយលទ្ធផលតាមគុណវិស័យសម្រាប់រៀបរាប់ពីការប្រមូលទិន្នន័យបន្ទាប់បន្សំ។ ការប្រមូលទិន្នន័យនេះ គឺធ្វើឡើងបានដោយផ្អែកទៅលើឯកសារមួយចំនួនដូចជា ការស្រាវជ្រាវក្នុងបណ្ណាល័យ សន្ធានុក្រមពន្ធដារ សៀវភៅច្បាប់ពន្ធដារនៅក្នុងសាកលវិទ្យាល័យវ៉ាន់ដា តាមរយៈគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ លិខិតបទដ្ឋាននៃអគ្គនាយកពន្ធដារដើម្បីធ្វើការសរសេរ និងយល់ដឹងបន្ថែមពីនីតិវិធីនៃការប្រមូលពន្ធអាករបំភ្លឺសាធារណៈ និងអាករពិសេស ។

- សម្រាប់សំណួរទី១ ៖ ត្រូវបានប្រមូលតាមរយៈគុណវិស័យ លិខិតបទដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ សៀវភៅច្បាប់ពន្ធដារកម្ពុជា នៃសាកលវិទ្យាល័យវ៉ាន់ដា និងយកតាមសិស្សច្បងដែលធ្វើសារណាជំនាន់មុនៗ ។
- សម្រាប់សំណួរទី២ ៖ ត្រូវបានប្រមូលតាមរយៈគុណវិស័យ លិខិតបទដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ សៀវភៅច្បាប់ពន្ធដារកម្ពុជានៃសាកលវិទ្យាល័យវ៉ាន់ដា និងយកតាមសិស្សច្បងដែលធ្វើសារណាជំនាន់មុនៗ ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ គឺជាការពង្រឹងនូវចំណេះដឹងដល់និស្សិតឱ្យមានភាពរីកចម្រើនជាច្រើនជាពិសេស ធ្វើឱ្យយើងទទួលបាននូវចំណេះដឹងថ្មីៗ បទពិសោធន៍ជាច្រើនទាក់ទង និងការស្រាវជ្រាវសម្រាប់ការសិក្សារបស់ខ្លួន និងក្នុងក្រុមរបស់យើងទាំងមូល ហើយក៏ជួយជម្រុញឱ្យមានការអភិវឌ្ឍសម្រាប់សង្គមយ៉ាងឆាប់រហ័សផងដែរ ។ មិនត្រឹមតែប៉ុណ្ណោះ ការសិក្សាស្រាវជ្រាវនេះក៏បានផ្តល់ចំណេះដឹងដូចជា ៖

- **សម្រាប់អ្នកស្រាវជ្រាវ**
  - យល់ដឹងកាន់តែច្បាស់អំពីអាករបំភ្លឺសាធារណៈ ហើយនិងអាករពិសេស
  - យល់ដឹងអំពីភាពខុសគ្នារវាងអាករបំភ្លឺសាធារណៈ និងអាករពិសេស
  - យល់ដឹងអំពីនិតិវិធីនៃការប្រមូលពន្ធអាករបំភ្លឺសាធារណៈ និងអាករពិសេស
  - យល់ដឹងពីអត្ថប្រយោជន៍របស់អាករភ្លឺសាធារណៈ និងអាករពិសេស
- **សម្រាប់ស្ថាប័ន**
  - រកដំណោះស្រាយ និងការដាក់ចេញនៃគោលនយោបាយនានាឱ្យកាន់តែប្រសើរឡើង
  - វិន័យ ឆន្ទៈ និងការងារមានភាពលឿនរហ័ស
  - រៀបចំផែនការបានច្បាស់លាស់ និងអនុវត្តផែនការចំគោលដៅ ។
- **សម្រាប់សង្គម**
  - ដើម្បីពង្រឹងនូវចំណេះដឹងឱ្យកាន់តែទូលំទូលាយ
  - បណ្តុះបណ្តាលធនធានមនុស្ស
  - ដើម្បីចែករំលែកចំណេះដឹងខាងការស្រាវជ្រាវជូនដល់និស្សិត អ្នកស្រាវជ្រាវ និងសាធារណជនទូទៅ ។

## ១.៧ រចនាសម្ព័ន្ធ

រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវនេះ គឺធ្វើឡើងក្នុងគោលបំណងឱ្យដឹងកាន់តែច្បាស់នៅចំណុចនីមួយៗដែលបានធ្វើឡើងដោយធ្វើការរាប់បញ្ចូលចំណុចដែលមានសេចក្តីផ្តើម គោលបំណងនៃការស្រាវជ្រាវ ទំហំដែនកំណត់នៃការស្រាវជ្រាវ វិសាលភាពនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ សេចក្តីសន្និដ្ឋាន អនុសាសន៍ និងមានចំណុចផ្សេងៗទៀត ។ ក្រោយពីបានសិក្សាស្រាវជ្រាវរួចមកក្រុមនាងខ្ញុំបានបែងចែកជា៥ជំពូកដូចជា ៖

**ជំពូកទី១៖ (សេចក្តីផ្តើម)** បង្ហាញអំពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណង ដែនកំណត់វិសាលភាពនៃការស្រាវជ្រាវ និងសារៈសំខាន់ដូចជា រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ។

**ជំពូកទី២៖ (រំលឹកទ្រឹស្តី)** បង្ហាញអំពីនិយមន័យ និងប្រវត្តិទូទៅដែលពាក់ព័ន្ធ និងទ្រឹស្តីរបស់អ្នកប្រាជ្ញដែលមានចំណេះដឹងពាក់ព័ន្ធ នឹងការសិក្សាស្រាវជ្រាវ ។

**ជំពូកទី៣៖ (លទ្ធផលនៃការស្រាវជ្រាវ)** បង្ហាញពីស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារទស្សនវិស័យ និងបេសកម្ម គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ ។

**ជំពូកទី៤៖ ការវិភាគពីចំណុចខ្លាំង និងចំណុចខ្សោយ** វិភាគនឹងធ្វើការស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយ ។

**ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍** ការសន្និដ្ឋានទៅលើចំណុចទាំងអស់ ដែលនៅក្នុងអត្ថបទ និងផ្តល់អនុសាសន៍ទៅលើចំណុចដែលមានកង្វះខាតដើម្បីធ្វើការកែលម្អ ។

# ជំពូកទី២

# ភាពខុសគ្នារវាងអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេស

## ២.១ លក្ខណៈទូទៅនៃអាករសម្រាប់បំភ្លឺសាធារណៈ

### ២.១.១ និយមន័យអាករ

- **អាករ** សំដៅដល់កាតព្វកិច្ចរបស់ប្រជាពលរដ្ឋ និងគ្រប់សមាសភាពសេដ្ឋកិច្ចត្រូវបង់សាច់ប្រាក់ ឬវត្ថុជូនរដ្ឋទៅតាមច្បាប់កំណត់ ដោយប្រយោលតាមការប្រើប្រាស់ទំនិញ ឬសេវាកម្ម ។ ហើយអាករក៏អាចត្រូវបានគេហៅថាជាពន្ធប្រយោល [1]។
- **អាករ** ជាប្រភេទពន្ធប្រយោល ដែលអ្នកជាប់ពន្ធបង់ពន្ធនេះដោយប្រយោលតាមការប្រើប្រាស់ទំនិញ និងសេវា ក្នុងនោះរួមមាន ។
  - អាករលើតម្លៃបន្ថែម
  - អាករបំភ្លឺសាធារណៈ
  - អាករពិសេសលើទំនិញ និងសេវាមួយចំនួន និងអាករស្នាក់នៅ ។
- **អាករ** មានន័យថាពន្ធប្រយោល ឬបន្ទុកប្រយោល ឬកាតព្វកិច្ចប្រយោលដែលតម្រូវឱ្យបង់ដោយប្រយោលពីអ្នកជាប់ពន្ធ[2]។

### ២.១.២ ប្រវត្តិនៃអាករ

ជាទូទៅអាករមាន 4 ប្រភេទគឺ ៖

- អាករពិសេស
- អាករសម្រាប់បំភ្លឺសាធារណៈ
- អាករលើតម្លៃបន្ថែម
- អាករលើការស្នាក់នៅ : សណ្ឋាគារ ផ្ទះសំណាក់(អត្រា 2%) ។

អាករលើតម្លៃបន្ថែម ជាអ្នកដែលជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលធ្វើការផ្គត់ផ្គង់ជាប់អាករត្រូវមានកាតព្វកិច្ចចុះបញ្ជីអាករលើតម្លៃបន្ថែម និងប្រមូលអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ទំនិញឬសេវាឱ្យអតិថិជន [3]។

អាករលើតម្លៃបន្ថែម គឺជាអាករកំណត់ទៅលើការចំណាយទិញរបស់ប្រើប្រាស់អាករនេះត្រូវប្រមូលពីការប្រកបអាជីវកម្ម និងការនាំចូល ។ ការប្រកបអាជីវកម្មភាគច្រើនដែលទាក់ទិនទៅ និងការផ្គត់ផ្គង់ទំនិញ ឬសេវា [4]។

ទំនិញ គឺសំដៅទៅដល់ទ្រព្យរូបីក្រៅពីដីធ្លី និងប្រាក់កាស រីឯសេវាសំដៅដល់ការផ្តល់អ្វីមួយដែលមានតម្លៃក្រៅពីទំនិញដីធ្លី និងប្រាក់កាស [5]។

❖ ការផ្គត់ផ្គង់ជាប់អាករសំដៅដល់ ៖

- ការផ្គត់ផ្គង់ទំនិញ ឬសេវាដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា

---

[1] Property. Sotheary. (2021, October 25 ). តើពន្ធនិ ងអាករខុសគ្នាយ៉ាងដូចម្តេច ? Retrieved from https://propertyarea.asia/archives/84407

[2] Facebook page. Social media. (2014, November 27) *សិក្សាស្វែងយល់ច្បាប់ស្តីពីពន្ធដារ*. Retrieved from https://www.facebook.com/share/p/1CBn9rxpFa/

[3] Share.Google. (2022). *អាករលើតម្លៃបន្ថែម*. Retrieved from https://share.google/qaTbrWcH8KrtbTFOt

[4] Facebook page. Social media. (2022, December 15). *អាករលើតម្លៃបន្ថែម*. Retrieved from https://www.facebook.com/share/1CQK6d866H/?mibextid=wwXIfr

[5] វិទ្យាស្ថាន វ៉ាន់ដា. (២០២៤). *ច្បាប់ពន្ធដារកម្ពុជា*. បោះពុម្ពលើកទី១. ទំព័រ៦៦. ភ្នំពេញ។

- ការដកយកទំនិញមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ
- ការផ្តល់ជាអំណោយ ឬការផ្គត់ផ្គង់ក្រោមតម្លៃពិតនូវទំនិញ ឬសេវាដោយបុគ្គលជាប់អាករ
- ការនាំចូលទំនិញមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា [6]។

❖ អត្រាអាករលើតម្លៃបន្ថែមមាន ៖

- ១០% សម្រាប់ការនាំចូលឬការផ្គត់ផ្គង់ទំនិញឬសេវាក្នុងព្រះរាជាណាចក្រកម្ពុជា
- ០% សម្រាប់ការនាំចេញអាករលើធាតុចូលដែលមិនអាចកាត់កងបានរួមមានប្រាក់អាករដែលបានបង់លើ ៖
- ចំណាយទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ លើកលែងតែបុគ្គលជាប់អាករមានអាជីវកម្មជាអ្នកផ្គត់ផ្គង់ ការ ទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ
- ការទិញ ឬនាំចូលរថយន្តលើកលែងតែបុគ្គលជាប់អាករប្រកបរអាជីវកម្មជាអ្នកលក់ ឬជួលរថយន្ត
- ការទិញ ឬនាំចូលផលិតផលតែលសិលាមួយចំនួន លើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មជាអ្នកផ្គត់ផ្គង់ផលិតផលតែលសិលាទាំងនោះ
- អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ជាប់អាករនូវទំនិញឬសេវាត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតគឺត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់[7]។

**២.១.៣ ទ្រឹស្តីនៃអាករ**

រៀបចំដោយលោកមេធាវី ឡាន ស៊ីនីត និងលោក លី លីនដូ ជាជំនួយការមេធាវី ហើយជាសមាជិកក្រុមការងារ។ ជាទូទៅ នៅពេលដែលយើងទិញទំនិញ ម្ហូបអាហារ ភេសជ្ជៈ ឬរបស់របរផ្សេងៗ ជាពិសេសនៅតាមបណ្តាផ្សារទំនើបផ្សេងៗ ឬភោជនីយដ្ឋានធំៗ គឺយើងតែងតែសង្កេតឃើញថាអ្នកលក់ទាមទារឱ្យអ្នកទិញត្រូវបង់ប្រាក់បន្ថែមចំនួន ១០% នៃប្រាក់ថ្លៃទំនិញដែលបានទិញនោះ ។ ប្រាក់បន្ថែមចំនួន ១០% ដែលត្រូវបង់នេះ គឺជាពន្ធដែលត្រូវប្រមូលដោយអ្នកលក់សម្រាប់យកទៅបង់ជូនរដ្ឋដែលត្រូវបានហៅថា អាករលើតម្លៃបន្ថែម (Value Added Tax or VAT) ។

យោងតាមទ្រឹស្តីអាករលើតម្លៃបន្ថែម គឺជាពន្ធលើការចំណាយរបស់អ្នកប្រើប្រាស់ចុងក្រោយដែលត្រូវគិតបន្ថែមលើតម្លៃដើមនៃផលិតផល ឬសេវាកម្មជាប់អាករ ។ ការប្រកបអាជីវកម្មភាគច្រើនទាក់ទិនទៅ នឹងការផ្គត់ផ្គង់ទំនិញ ឬសេវាហើយការប្រកបអាជីវកម្មទាំងនោះត្រូវជាប់ អតប ប្រសិនបើមានការផ្គត់ផ្គង់ ។

នៅក្នុងអត្ថបទមួយនេះ នឹងយកចំណុចសំខាន់អំពី អតប ចំនួន ៣ ចំណុចយកមកបកស្រាយដោយមិនបូកបញ្ចូល ការស្នើសុំឥណទាន វិធាន និងនីតិវិធីសម្រាប់ អតប នោះទេ ។ ចំណុចទាំង៣ នោះមានដូចជា ៖ (១)បុគ្គលជាប់អាករ និងកាតព្វកិច្ច (២) ការផ្គត់ផ្គង់ជាប់អាករ និងការផ្គត់ផ្គង់មិនជាប់អាករ (៣) អត្រាអាករ ។

១៖ បុគ្គលជាប់អាករ គឺបុគ្គលជាប់ពន្ធតាមរបបស្វ័យប្រកាសនិងធ្វើការផ្គត់ផ្គង់ជាប់អាករ។ បុគ្គលជាប់អាករមានដូចជា ក្រុមហ៊ុននីតិបុគ្គលគ្រប់ប្រភេទ សហគ្រាសវិនិយោគទាំងអស់ និងសហគ្រាសនីហរ័ណ្ណអាហរ័ណ្ណដែលធ្វើការផ្គត់ផ្គង់ជាប់អាករ ។ សហគ្រាសដទៃទៀតដែលមាន៣ចំណាត់ថ្នាក់ជាអ្នកដែលជាប់ពន្ធតាមរបបស្វ័យប្រកាសដែលមានផលរបរប្រចាំឆ្នាំពីការផ្គត់ផ្គង់ទំនិញ និងសេវាដូចខាងក្រោម ៖

---

[6] KHsearch. ពន្ធ. (2020, March 10). *តើការផ្គត់ផ្គង់ជាប់អាករសំដៅដល់អ្វីខ្លះ?* Retrieved from https://www.khsearch.com/qna/30084

[7] Business. (2022). *អ្នកជាប់ពន្ធ*. Retrieved from https://www.business.gov.kh/business-process/tax/value-added-tax

ក. អ្នកជាប់ពន្ធតូច គឺជាសហគ្រាសឯកបុគ្គលឬសហគ្រាសសហកម្មសិទ្ធិមានផលរបរចាប់ពី ២៥០លាន ដល់៧០០លានក្នុង ១ឆ្នាំ

ខ. អ្នកជាប់ពន្ធមធ្យម មានផលរបរចាប់ពី ៧០០លាន ដល់៤,០០០លាន ក្នុង១ឆ្នាំ

គ. អ្នកជាប់ពន្ធធំ មានផលរបរលើសពី ៤,០០០លាន ក្នុង១ឆ្នាំ ។

បន្ថែមពីនេះសហគ្រាសដទៃទៀតអាចចុះបញ្ជី អតប ដោយស្ម័គ្រចិត្តប្រសិនបើវាមានផលប្រយោជន៍ដល់ខ្លួន និងស្ថាប័នរដ្ឋាភិបាលទាំងអស់ដែលធ្វើសកម្មភាពអាជីវកម្មត្រូវសុំចុះបញ្ជី អតប និងបុគ្គលដទៃទៀតដែលអគ្គនាយដ្ឋានពន្ធដារ (អនពដ) ចុះបញ្ជីជាឯកតោភាគី ។

ចំណែកឯកាតព្វកិច្ចមានដូចជាកាតព្វកិច្ចក្នុងការចុះបញ្ជីប្រសិនបើស្ថិតក្នុង និងធ្វើការផ្គត់ផ្គង់ជាប់ អតប និងត្រូវដាក់តាំងវិញ្ញាបនបត្រចុះបញ្ជី អតប នៅទីកន្លែងអាជីវកម្ម ។ បុគ្គលជាប់ អតប ត្រូវគិត អតប លើអតិថិជនទាំងអស់ចាប់ពីកាលបរិច្ឆេទមានប្រសិទ្ធិភាព និងចេញវិក្កយបត្រ អតប ដល់អតិថិជនដែលជាបុគ្គលជាប់អាករចេញវិក្កយបត្រធម្មតាដល់អតិថិជនដែលជាបុគ្គលមិនជាប់អាករ ។

ការចុះបញ្ជី អតប ត្រូវធ្វើមុនពេលអ្នកជាប់ពន្ធអាចនាំចូល និងនាំចេញសម្រាប់គោលដៅអាជីវកម្ម ។ ត្រូវរក្សាកំណត់ត្រា និងគណនីទាក់ទិននឹង អតប សម្រាប់រយៈពេល ១០ឆ្នាំ និងដាក់លិខិតប្រកាស អតប និងបង់ប្រាក់ពន្ធដែលប្រកាសប្រចាំខែត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែជាប់ពន្ធ ។ ហើយធ្វើការជូនដំណឹងដល់អគ្គនាយកដ្ឋានពន្ធដារអំពីការប្រែប្រួលស្ថានភាពអាជីវកម្មរួមមានការផ្ទេរអាជីវកម្ម ឬការស្នើសុំលុបចោលការចុះបញ្ជីអតប ។ អនុញ្ញាតឱ្យមន្ត្រីអគ្គនាយកដ្ឋានពន្ធដារពិនិត្យមើលកំណត់ឯកសារ និងទីតាំងអាជីវកម្មសហគ្រាស ។

២៖ ការផ្គត់ផ្គង់ជាប់អាករមានដូចជា ការផ្គត់ផ្គង់ទំនិញ ឬសេវាដោយបុគ្គលជាប់ អតប នៅកម្ពុជា និងការដកទំនិញមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់ អតប ។ ការផ្តល់ជាអំណោយ ឬផ្គត់ផ្គង់ក្រោមតម្លៃពិតនូវទំនិញ និងសេវាដោយបុគ្គលជាប់ អតប និងការនាំចូលទំនិញចូលមកក្នុងតំបន់ត្រួតពិនិត្យគយកម្ពុជា ។ ការផ្គត់ផ្គង់មិនជាប់អាករ មានដូចជា ៖

- សេវាប្រៃសណីយ៍សាធារណៈ
- សេវាមន្ទីរពេទ្យ និងគ្លីនិក សេវាខាងវេជ្ជសាស្ត្រ និងទន្តសាស្ត និងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រ ដែលទាក់ទិន នឹងការបំពេញសេវាកម្មទាំងនេះ
- សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ
- សេវាធានារ៉ាប់រង
- សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការនាំចូល ឬផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ
- សេវាសិក្សាអប់រំ
- ថាមពលអគ្គីសនី និងទឹកស្អាត
- សេវាប្រមូល ឬសម្អាតកាកសំណល់រឹង-រាវ
- ការនាំចូលរបស់របរប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយ

- សកម្មភាពមិនស្វែងរកប្រាក់ចំណេញដើម្បីប្រយោជន៍សាធារណៈ
- ការនាំចូល ឬទិញទំនិញសម្រាប់យកមកបំពេញមុខងារជាផ្លូវការរបស់បេសកកម្មការទូត និងកុងស៊ុល បរទេសអង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។

៣៖ អត្រាអាករនៃ អតប ក្នុងប្រទេសកម្ពុជាត្រូវបានកំណត់អត្រា ១០% ទៅលើការផ្គត់ផ្គង់លើអាករដែលមានដូចជា ការផ្គត់ផ្គង់ក្នុងស្រុក និងទំនិញនាំចូល។ ចំពោះការនាំទំនិញចេញពីព្រះរាជាណាចក្រកម្ពុជា ការផ្គត់ផ្គង់សេវាជាប់អាករដែលបានធ្វើនៅក្រៅព្រះរាជាណាចក្រកម្ពុជា និងការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរជាអន្តរជាតិព្រមទាំងទំនិញ និងសេវាដែលទាក់ទិននឹងការនាំចេញ និងការដឹកជញ្ជូនអ្នកដំណើរជាអន្តរជាតិត្រូវជាប់អាករតាមអត្រា០% ។

សរុបមក អតប គឺជាកាតព្វកិច្ចរបស់គ្រប់សមាសភាពដូចបានកំណត់ដោយច្បាប់ ដើម្បីជាការរួមចំណែកដល់ប្រទេសជាតិហើយរាល់ការអនុវត្ត អតប ត្រូវអនុវត្តតាមការកំណត់ក្នុងច្បាប់ស្តីពីសារពើពន្ធ និងប្រកាសស្តីពីអាករលើតម្លៃបន្ថែម របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ [8]។

## ២.២ ភាពខុសគ្នារវាងអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេស

### ២.២.១ និយមន័យអាករពិសេស

- អាករពិសេស គឺជាពន្ធប្រចាំខែដែលត្រូវបានគិតលើផលិតផលក្នុងស្រុក ផលិតផលនាំចូល និងសេវាកម្មមួយចំនួន ។ អ្នកជាប់ពន្ធក្នុងស្រុកដែលផលិតផ្គត់ផ្គង់ទំនិញ ឬសេវាកម្មទាំងនេះ ត្រូវទទួលខុសត្រូវចំពោះការបង់អាករប្រភេទនេះ [9]។
- អាករពិសេស គឺអនុវត្តលើទំនិញ ឬសេវាមួយចំនួនដែលមានលក្ខណៈប្រណិត ឬមិនមែនជាតម្រូវការចាំបាច់ក្នុងជីវភាពប្រចាំថ្ងៃ ឬប៉ះពាល់ដល់សុខភាព សង្គម ឬបរិស្ថាន[10] ។
- អាករពិសេស គឺជាប្រភេទពន្ធប្រយោលដែលត្រូវបានប្រមូលលើទំនិញ និងសេវាមួយចំនួនពីអ្នកប្រើប្រាស់តាមរយៈអ្នកផលិត ឬអ្នកផ្គត់ផ្គង់ [11]។
- អាករពិសេស គឺយកទៅលើទំនិញ និងសេវាមួយចំនួនត្រូវបានកំណត់លើទំនិញ និងសេវាមួយចំនួន ។ ទំនិញដែលជាប់អាករនេះរួមមានស្រា(៣៤%) ស្រាបៀរ(៣០%) និងបារី(20%) ។ ចំពោះសេវាដែលជាប់អាករនេះមានសេវាលំហែកម្សាន្ត សេវាដឹកអ្នកដំណើរតាមផ្លូវអាកាស (១០%) និងសេវាទូរស័ព្ទ(៣%) ។ អ្នកជាប់ពន្ធដលផលិតទំនិញ ឬផ្គត់ផ្គង់សេវាទាំងនេះត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករនេះជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលផ្គត់ផ្គង់[12]។

### ២.២.២ ប្រវត្តិនៃអាករពិសេស

ដើមកំណើតអាករពិសេសនៅលើពិភពលោក ៖

[8] Fresh News. (2022, July 03). *អាករលើតម្លៃបន្ថែម.* Retrieved from https://m.freshnewsasia.com/freshnewsplus/247924-2022-07-03-10-56-22.html

[9] Facebook page. Richeng Tax and Accounting Firm. (2024, November 21). *អាករពិសេស.* Retrieved from https://www.facebook.com/share/p/1Bw2ZmoA1Q/

[10] វិទ្យាស្ថាន វ៉ាន់ដា. (២០២៤). *ច្បាប់ពន្ធដារកម្ពុជា.* បោះពុម្ពលើកទី១ ទំព័រ៩៣. ភ្នំពេញ។

[11] KHsearch. ពន្ធ. (2020, January 21). *ដូចម្តេចហៅថាអាករពិសេសលើទំនិញនិងសេវាមួយចំនួន?* Retrieved from https://www.khsearch.com/qna/28557

[12] Business.gov. (២០២២). *អាករពិសេស.* Retrieved from https://www.business.gov.kh/business-process/tax/special-tax

- អង់គ្លេសត្រូវបានគេចាត់ទុកថាជា ប្រទេសដំបូងនៅអឺរ៉ុប ដែលអនុវត្ត Excise Tax សម័យទំនើប ដោយច្បាស់លាស់នៅឆ្នាំ ១៦៤៣ ក្នុងសម័យសង្គ្រាមស៊ីវិល (English Civil War)។
- អាមេរិក ប្រទេសនេះបានអនុវត្តអាករពិសេសដំបូងលើស្រាបៀរ និងរមៀតនៅឆ្នាំ ១៧៩១ (ហៅថា Whiskey Tax) ដោយរដ្ឋាភិបាលដើម្បីផ្គត់ផ្គង់ថវិកាដល់រដ្ឋថ្មី ។

អាករពិសេសនៅកម្ពុជាមានដើមកំណើត ៖

**១. អាករពិសេសនៅសម័យអង្គរ (ស.វ ៩-១៥)**

- នៅសម័យអង្គរ មានការប្រមូលអាករពិសេសលើ អំបិល ស្រា និងផលិតផលកសិកម្មខ្លះ
- អាចមានការដាក់អាករលើផលិតផលប្រើប្រាស់ប្រចាំថ្ងៃដើម្បីគាំទ្ររាជវង្ស និងការស្ថាបនាអគារយ៉ាងធំ
- មានប្រព័ន្ធចែកចាយទំនិញកាន់តែរីកចម្រើនដែលអាចជាមូលហេតុនៃការដាក់អាករពិសេស ។

**២. សម័យអាណានិគមបារាំង (១៨៦៣-១៩៥៣)**

- អ្នកអាណានិគមបារាំងបាននាំមកនូវប្រព័ន្ធពន្ធទំនើប និងច្បាប់អាករពិសេស
- ពីសតវត្សទី១៩ បារាំងដាក់អាករពិសេសលើស្រា បារី និងអំបិលដើម្បីបង្កើតប្រាក់ចំណូលសម្រាប់រដ្ឋអាណានិគម
- ពលរដ្ឋត្រូវបង់អាករនៅតាមទីផ្សារ និងពេលនាំចេញទំនិញខ្លះ ។

**៣. សម័យឯករាជ្យ និងសង្គ្រាមស៊ីវិល (១៩៥៣-១៩៩៣)**

- បន្ទាប់ពីឯករាជ្យ (១៩៥៣) រដ្ឋាភិបាលបានបន្តប្រព័ន្ធអាករពិសេស ប៉ុន្តែមានការកែប្រែតាមតម្រូវការសេដ្ឋកិច្ច
- សម័យសង្គ្រាម និងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ប្រព័ន្ធអាករបានរលូនបោល
- បន្ទាប់ពី ១៩៧៩ (សម័យកម្ពុជាប្រជាធិបតេយ្យ) មានការផ្ទេរពាណិជ្ជកម្មទៅរដ្ឋ ប៉ុន្តែមានការដាក់អាករពិសេសលើទំនិញមួយចំនួន ។

**៤. អាករពិសេសនៅសម័យអំឡុងឆ្នាំ ១៩៩៣-បច្ចុប្បន្ន**

- បន្ទាប់ពីកម្ពុជាទៅរកសេដ្ឋកិច្ចទីផ្សារ (១៩៩៣)ប្រព័ន្ធពន្ធ និងអាករត្រូវបានកែសម្រួល
- ច្បាប់អាករពិសេស (Excise Tax Law) ត្រូវបានអនុម័តដើម្បីបង្កើតប្រាក់ចំណូលសម្រាប់រដ្ឋ
- អាករពិសេសត្រូវបានដាក់លើ ស្រា បារី សាំង ឡាន និងសេវាកម្សាន្ត
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករ (General Department of Customs and Excise) គ្រប់គ្រងការប្រមូលអាករពិសេស ។

**សន្និដ្ឋាន**

- អាករពិសេសនៅកម្ពុជាមានដើមកំណើតពីសម័យអង្គរ ហើយត្រូវបានអភិវឌ្ឍក្នុងសម័យបារាំង និងបន្តកែលម្អក្រោយឯករាជ្យ
- បច្ចុប្បន្នអាករនេះជាមធ្យោបាយសំខាន់ក្នុងការបង្កើតប្រាក់ចំណូលរដ្ឋ និងគ្រប់គ្រងការប្រើប្រាស់ទំនិញពិសេស ។

### ២.២.៣ ទ្រឹស្តីអាករពិសេស

ទ្រឹស្តីអាករពិសេស (Excise Tax Theory) ត្រូវបានសិក្សាដោយអ្នកសេដ្ឋកិច្ចជាច្រើន ។ ទោះបីជាមិនមានអ្នកនិយាយជាច្បាស់ថាជាបុគ្គល ដែលបង្កើតទ្រឹស្តីអាករពិសេសលើកដំបូងក៏ដោយប៉ុន្តែទ្រឹស្តីនឹងអំពូលគំនិតរបស់អ្នកសេដ្ឋកិច្ចដូចជា Adam Smith, Arthur Pigou និង David Ricardo ។

1. Adam Smith (១៧២៣-១៧៩០) – ទ្រឹស្តីសេដ្ឋកិច្ចដំបូង
   - Adam Smith ជាសាស្ត្រាចារ្យសេដ្ឋកិច្ចអង់គ្លេស ដែលបាននិយាយអំពីពន្ធក្នុងសៀវភៅ “ The Wealth of Nations ” (១៧៧៦)
   - គាត់បានលើកឡើង ថាពន្ធគួរត្រូវបានដាក់លើទំនិញសហសាធារណៈ និងទំនិញដែលមានផលប៉ះពាល់លើសង្គម
   - គំនិតរបស់គាត់ជាមូលដ្ឋានសម្រាប់រដ្ឋនីមួយៗក្នុងការដាក់អាករពិសេសលើផលិតផលដែលមានគុណប្រយោជ្ន៍ ឬអវិជ្ជមាន
2. Arthur Pigou (១៨៧៧-១៩៥៩) – ទ្រឹស្តី Externalities និង Pigovian Tax
   - Arthur Pigou ជាអ្នកសេដ្ឋកិច្ចអង់គ្លេស ដែលបានអភិវឌ្ឍ “ Pigovian Tax ” ដែលជាការដាក់ពន្ធលើទំនិញដែលបង្កផលប៉ះពាល់អវិជ្ជមានដល់សង្គម
   - គាត់បានពន្យល់ថាប្រសិនបើផលិតផល ឬសេវាកម្មណាមួយបង្កឱ្យមានផលប៉ះពាល់អវិជ្ជមាន ( ដូចជា បារី ឬកង្វះបរិស្ថាន ) រដ្ឋគួរតែដាក់ពន្ធលើវាដើម្បីកាត់បន្ថយការប្រើប្រាស់
   - នេះជាគំនិតសំខាន់ដែលជាស្តង់ដារដើម្បីអនុវត្តអាករពិសេសនៅក្នុងប្រទេសជាច្រើន ។
3. David Ricardo ( ១៧៧២-១៨២៣ ) – ទ្រឹស្តីសេដ្ឋកិច្ច និងពន្ធ
   - David Ricardo ជាអ្នកសេដ្ឋកិច្ចដែលបានសិក្សាពីវិធីដែលពន្ធអាចប៉ះពាល់ដល់ការផលិត និងការលក់ផលិតផល
   - គាត់បានអះអាងថា ពន្ធដែលដាក់លើផលិតផលអាចប៉ះពាល់ដល់ការរីកចម្រើនសេដ្ឋកិច្ចដូច្នេះគួរតែមានការតុល្យាឱ្យសមរម្យ ។

**សរុប**

ទោះបីជា Adam Smith, Arthur Pigou និង David Ricardo មិនបានបង្កើតទ្រឹស្តីអាករពិសេសផ្ទាល់ក៏ដោយ ប៉ុន្តែ ពួកគាត់បានបង្កើតគំនិតសំខាន់ដែលមានឥទ្ធិពលដល់ការអនុវត្តអាករពិសេសនៅសម័យបច្ចុប្បន្ន។ ក្នុងចំណោមពួកគាត់ Arthur Pigou គឺជាអ្នកដែលមានឥទ្ធិពលខ្លាំងជាងគេដោយសារការពន្យល់អំពី Pigovian Tax

នៅកម្ពុជា អាករពិសេសត្រូវបានគ្រប់គ្រងដោយ អគ្គនាយកដ្ឋានពន្ធដារ (GDT) និងត្រូវបានគ្រប់គ្រងតាមច្បាប់ស្តីពីអាករពិសេស ។ វាត្រូវបានអនុវត្តលើផលិតផល និងសេវាកម្មជាក់លាក់ ដូចជា ៖

- ទឹកស៊ីជា និងភេសជ្ជៈដែលមានជាតិស្ករ
- ម្សៅគ្រឿងស្រវឹង និងស្រា
- បារី និងផលិតផលជក់

- ឥន្ធនៈ និងរថយន្ត

**សរុបៈ** ទ្រឹស្តីអាករពិសេសបង្ហាញពីវិធីដែលរដ្ឋប្រើប្រាស់ការដាក់ពន្ធលើទំនិញ ឬសេវាកម្មដើម្បីបង្កើនប្រាក់ចំណូល និងគ្រប់គ្រងសង្គម ។ វាមានឥទ្ធិពលដល់អ្នកប្រើប្រាស់ អ្នកផលិត និងសេដ្ឋកិច្ចទាំងមូល ។

## ២.៣ នីតិវិធីនៃការប្រមូលពន្ធលើអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេស

### ២.៣.១ និយមន័យនីតិ

- **នីតិ** ជាវិធានទាំងអស់ដែលគ្រប់គ្រងការរស់នៅក្នុងសង្គមហើយដែលត្រូវអនុវត្ត និងផ្តន្ទាទោសដោយអំណាចសាធារណៈ [13]។
- **នីតិ** វាខុសពីប្រពៃណី ទំនៀមទម្លាប់ សីលធម៌ និងសាសនាព្រោះនីតិត្រូវបានជានាការអនុវត្តដោយអំណាចរដ្ឋ ។
- **នីតិ** វាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងសីលធម៌ក៏ដូចជាសាសនា ។
- **នីតិ** គឺជាវិទ្យាសាស្ត្រច្បាប់សិក្សាលើសំណុំវិធានទាំងឡាយដែលមនុស្សជាអ្នកបង្កើតឡើងដើម្បីគ្រប់គ្រងការរស់នៅ និងគ្រប់គ្រងទំនាក់ទំនងរបស់មនុស្សក្នុងសង្គមតាមរយៈការអនុវត្ត និងផ្តន្ទាទោសដោយអំណាចសាធារណៈ ។ លើសពីនេះទៀត នីតិជាមធ្យោបាយដោះស្រាយទំនាស់ក្នុងសង្គម [14]។

### ២.៣.២ ប្រវត្តិរបស់នីតិ

នីតិអន្តរជាតិកើតឡើងពីទំនាក់ទំនងរវាងសង្គមជាតិមួយ និងសង្គមជាតិមួយទៀត ។ នៅពេលដែលមនុស្សចាប់ផ្តើមទទួលស្គាល់ថាមានក្រុមមនុស្សដទៃទៀតនៅលើផែនដីហើយចាប់ផ្តើមមានទំនាក់ទំនងជាមួយគ្នារវាងមនុស្សមួយក្រុម និងមួយក្រុមទៀតពួកគេបានបង្កើតវិធានគ្រប់គ្រងទំនាក់ទំនងទាំងនោះ ។ បន្ទាប់មកវិធានទាំងនោះភាគច្រើនបានក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ប្រព័ន្ធនីតិអន្តរជាតិបច្ចុប្បន្ន ។

**១. នីតិអន្តរជាតិបុរាណ**

គេបានកត់សម្គាល់ថា សន្ធិសញ្ញាដែលចុះនៅប្រមាណឆ្នាំ ២១០០ មុនគ្រិស្តសករាជរវាងរដ្ឋនានានៅភាគខាងកើតមហាសមុទ្យមេឌីទែរ៉ានេដោយផ្អែកលើគោលការណ៍ Pacta Sunt Servanda និងគោលការណ៍សុទ្ធចិត្ត ( Good Faith ) គឺជាសន្ធិសញ្ញាដំបូងគេ នៅក្នុងនីតិអន្តរជាតិ ។

ក្រៅពីនេះគេសង្កេតឃើញថាប្រទេសក្រិចបុរាណ (ប្រមាណ ១១០០ឆ្នាំ មុនគ្រិស្តសករាជដល់ ១៤៦ ឆ្នាំមុនគ្រិស្តសករាជ) បានបង្កើតប្រព័ន្ធមជ្ឈត្តកម្មជឿនលឿន និងស្ថាប័នបដិសណ្ឋារកិច្ចរដ្ឋក្នុងគោលបំណងការពារជនបរទេស ។ មិនតែប៉ុណ្ណោះក្រិចបុរាណបានបង្កើតវិធានគ្រប់គ្រងឥរិយាបថ ( Rule 0f conduct ) នៅពេលមានសង្គ្រាមក្នុងគោលបំណងហាមឃាត់ការប្រើប្រាស់អំពើឃោរឃៅនៅតាមក្រុងនានានៃរដ្ឋក្រិចបុរាណដោយកំណត់ថានៅក្នុងករណីណាដែល វាយដណ្តើមយកបានទីក្រុងណាមួយត្រូវទុកជីវិតឱ្យជនភៀសខ្លួននោះចំណែកឈ្លើយសង្គ្រាមត្រូវយកទៅដូរជាប្រាក់ ឬដោះដូរយកទៅធ្វើជាទាសករជាដើមប៉ុន្តែមិនត្រូវសម្លាប់ពួកគេនោះឡើយ ។

ចំណែកឯនៅចក្រភពរូមបុរាណ មុនពេលដែលគេពង្រីកអំណាចទៅតំបន់ផ្សេងៗលើពិភពលោក បានមានទំនាក់ទំនង និងបង្កើតជាសន្ធិសញ្ញាមួយចំនួនជាមួយតំបន់នានាដែលនិយាយភាសាឡាតាំងរួមមានទីក្រុង

[13] វិទ្យាស្ថាន វ៉ាន់ដា. (២០២៤) *សេចក្តីផ្តើមនីតិ.* បោះពុម្ពលើកទី៥. ទំព័រ៤. ភ្នំពេញ។
[14] វិទ្យាស្ថាន វ៉ាន់ដា. (២០២៤) *សេចក្តីផ្តើមនីតិ.* បោះពុម្ពលើកទី៥. ទំព័រ៣. ភ្នំពេញ។

នានាដែលនៅជុំវិញចក្រភពរូមតំបន់ឡាទៀម (Latium Region) តំបន់ដទៃទៀត ។ ក្រោយពីបានពង្រីកអំណាច ចក្រភពរូមបានគ្រប់គ្រងទំនាក់ទំនងរបស់ខ្លួនជាមួយតំបន់នានា ដោយផ្អែកលើគោលការណ៍ jus fetiale និង jus gentium ។ គោលការណ៍ jus fetiale ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងទំនាក់ទំនងការទូត និងសង្រ្គាម ដែលសំដៅដល់ការមិនបំពានដល់ឯកអគ្គរាជទូតរបស់ខ្លួន ។ ចំណែកគោលការណ៍ jus gentium យើងអាចបកប្រែសាមញ្ញថា "ច្បាប់ប្រជាជាតិ-Law of Nations" សំដៅថាប្រជាជាតិ ឬរដ្ឋទាំងអស់មានភាពស្មើគ្នានៅក្នុងកិច្ចការទំនាក់ទំនងគ្នាទៅវិញទៅមក ។ ក្រៅពីគោលការណ៍ទាំងពីរនេះចក្រភពរូមបានបង្កើតគោលការណ៍ជាច្រើនទៀត សម្រាប់គ្រប់គ្រងទំនាក់ទំនងរបស់ខ្លួនក្នុងវិស័យនានាមានដូចជាគោលការណ៍ just civile សំដៅដល់ភាពស្មើគ្នារវាងបុគ្គលម្នាក់ៗ និងគោលការណ៍ bona fides សំដៅដល់ការគោរពគ្នាទៅវិញទៅមកដោយសុទ្ធចិត្តជាដើម ។

**២. នីតិអន្តរជាតិសម័យកណ្តាល**

នៅសម័យកណ្តាល គេសង្កេតឃើញមានការអភិវឌ្ឍនីតិអន្តរជាតិលើគោលការណ៍ពីរដែលគួរឱ្យកត់សម្គាល់ នោះគឺៈ ច្បាប់ជំនួញអន្តរជាតិ (Lex mercatoria) និងច្បាប់ទម្លាប់សមុទ្ទដែលគោលការណ៍ទាំងពីរនេះពាក់ព័ន្ធទៅ នឹងការកំណត់ព្រំដែនរបស់ប្រជាជាតិនានា[15]។

**២.៣.៣ ទ្រឹស្តីទាក់ទងនឹងនីតិ**

មូលដ្ឋានគ្រឹះរបស់ច្បាប់ត្រូវកត់សម្គាល់យ៉ាងច្បាស់ជាងនេះទៅទៀត គឺជាបទដ្ឋានច្បាប់ (Nom of law) មនសិការច្បាប់ (Legal Consciousness) ទំនាក់ទំនងច្បាប់ (Legal Relation) ដែលទ្រឹស្តីបទដ្ឋាន ទ្រឹស្តីចិត្តសាស្ត្រទ្រឹស្តីសង្គមសាស្ត្រត្រូវបានបង្កើបឡើង ។ ទ្រឹស្តីបទដ្ឋាន (Nomative Theory) ដែលបានកើតឡើងនៅលើមូលដ្ឋាននៃការបង្ហាញឱ្យឃើញច្បាប់គឺជាបណ្តុំ ឬពហុភាពនៃបទដ្ឋានដែលស្តែងចេញមកខាងក្រៅនៅក្នុងច្បាប់ និងនៅក្នុងលិខិតបទដ្ឋានផ្សេងទៀត ។ តាមទស្សនៈ លោក **កែល សិន** ដែលជាអ្នកបង្កើតស្នាដៃនៃទស្សនាទាននេះទុកថាច្បាប់នាំមកនៅរចនាសម្ព័ន្ធពីរ៉ាមីតមួយប្រកបដោយនិយ័តភាព និងមានឋានានុក្រមច្បាស់លាស់ជាមួយ និងជាតុដែលមាននំនាក់ទំនង់ផ្សារជាប់គ្នាទៅ និងបទដ្ឋានគ្រឹះពីលើ ។ កម្លាំងនីត្យានុកូល និងនិត្យានុកូលភាពរបស់បទដ្ឋាននីមួយៗទំនាក់ទំនង់ទៅ និងបរិមានុភាពនៅលើពារ៉ាមីតនៃបទដ្ឋានដែលមានកម្រិតកម្លាំងនិត្យានុកូលខ្ពស់បំផុត ។ កាលយល់ដឹងទាន់សម័យអំពីច្បាប់ក្នុងក្របខណ្ឌនៃទ្រឹស្តីនេះអាចឆ្លុះបញ្ចាំងឱ្យឃើញនៅគំរូ បំព្រួញដូចតទៅៈ ក. ច្បាប់-គឺជាប្រព័ន្ធបទដ្ឋានដែលមានចំណងទំនងគ្នាទៅវិញទៅមក និងសកម្មភាពទៅវិញទៅមកដែលបង្ហាញគំនិត។

[15] Share.google. (2021, November 28). *នីតិអន្តរជាតិសម័យកណ្តាល.* Retrieved from https://share.google/DIyIB0TOpj4eDHtL

# ជំពូកទី៣
# ភាពខុសគ្នារវាងអាករសម្រាប់បំភ្លឺសារធារណៈ និងអាករពិសេស នៃអគ្គនាយកដ្ឋានពន្ធដារ

## ៣.១ ស្ថានភាពទូទៅនៃអាករបំភ្លឺសារធាណៈ

### ៣.១.១ប្រវត្តិរបស់អាករបំភ្លឺសារធាណៈ




នៅក្នុងឆ្នាំ១៩៥៣ នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើង ។ នៅក្នុងឆ្នាំ១៩៧៥ ដល់១៩៧៩ ប្រព័ន្ធពន្ធដារត្រូវបានលុបបំបាត់ចោលទាំងស្រុងដោយសារការកើតឡើងនូវសង្គ្រាមរបបប្រល័យពូជសាសន៍ (ប៉ុលពត ឬខ្មែរក្រហម) និងបានធ្វើឱ្យប្រជាជនជួបនូវភាពលំបាក និងការបាត់បង់ជីវិតជាច្រើននាក់ផងដែរ ។ ប្រព័ន្ធពន្ធដារត្រូវបានបង្កើតឡើងវិញដំបូងនៅឆ្នាំ១៩៨២ ដែលបានបង្កើតឡើងនៅរាជធានីភ្នំពេញ និងខេត្តចំនួន១០ផ្សេងទៀតដែលគេហៅថា របបម៉ៅការហើយបានគ្រប់គ្រង់ដោយនាយកដ្ឋានពន្ធដារ ។ លើសពីនេះទៅទៀត នាយកដ្ឋានបានបង្កើតពន្ធមួយចំនួនផ្សេងទៀតដើម្បីអនុវត្តដូចជាមានការចែងច្បាប់ និងមាត្រាយ៉ាងច្បាស់លាស់ ។ ហើយបានគ្រប់គ្រងដោយនាយកដ្ឋានពន្ធដារក្នុងគោលបំណងបង្កើតចំណូលថវិកាជាតិសម្រាប់ចំណាយផ្សេងៗ ដោយពុំចាំបាច់មានការបោះពុម្ពលុយដែលអាចធ្វើឱ្យកើតមានអតិផរណា ។ ជាងនេះទៅទៀតអគ្គនាយកពន្ធដារក៏បានបង្កើតពន្ធមួយចំនួនផ្សេងទៀតដើម្បីអនុវត្ត និងមានការចែងច្បាប់និងមាត្រាយ៉ាងច្បាស់លាស់ ។ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ ប្រកាសឱ្យប្រើដោយព្រះរាជក្រម

លេខ នស/រមក/០១.៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ចែងអំពីការអនុញ្ញាតប្រមូលឱ្យអាករបំភ្លឺសាធារណៈលើតម្លៃសុរាមេរ័យ និងបារី ដែលជាផលិតផលមកពីបរទេស ។

### ៣.១.២ បេសកកម្ម និងទស្សនៈវិស័យរបស់អាករសម្រាប់បំភ្លឺសាធារណៈ

#### ក.ទស្សនវិស័យ

អាករបំភ្លឺសាធារណៈអនុវត្តចំពោះផ្គត់ផ្គង់សុរាមេរ័យ (គ្រឿងស្រវឹង) និងបារីបន្ទាប់ពីនាំចូល ឬផលិតក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បី ជាប្រយោជន៍ដល់ថវិកាថ្នាក់ក្រោមជាតិសម្រាប់បំភ្លឺសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា ។

អាករបំភ្លឺសាធារណៈ គឺគណនាអាករត្រូវបង់បុគ្គលិកជាប់អាករត្រូវធ្វើការបែកចែកឲ្យបានរវាងផលរបរដែលបានមកពីការផ្គត់ផ្គង់សុរាមេរ័យ និងបារីជាប់អាករ និងផលរបរបានមកពីរការផ្គត់ផ្គង់ទំនិញ ឬសេវាដទៃទៀត ។

#### ខ.បេសកកម្ម

❖ សកម្មភាព

អាករបំភ្លឺសាធារណៈត្រូវបានកំណត់ដូចខាងក្រោម ៖

- ចំពោះអ្នកផលិត និងអ្នកនាំចូលមូលដ្ឋានគិតអាករគឺជាថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាលើវិក្កយបត្ររួមបញ្ចូលទាំងពន្ធអាករនានា វាលើកលែងតែអាករលើតម្លៃបន្ថែម និងអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង
- ចំពោះអ្នកផ្គត់ផ្គង់បន្តមូលដ្ឋានគិតអាករស្មើនឹង២០% នៃថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាលើកលែងវិក្ក័យបត្ររួមបញ្ចូលទាំងពន្ធអាករនានាវាលើកលែងតែអាករលើតម្លៃបន្ថែម និងអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង ។

អាករបំភ្លឺសាធារណៈ គឺជាអាករមួយប្រភេទដែលបង្កើតឡើងដើម្បីជាប្រយោជន៍ដល់ថវិកាថ្នាក់ក្រោមជាតិសម្រាប់បំភ្លឺផ្លូវសាធារណៈទូទាំងប្រទេស ។ អាករប្រភេទនេះត្រូវបានកំណត់លើគ្រប់ដំណាក់កាលនៃការផ្គត់ផ្គង់សុរាមេរ័យ (គ្រឿងស្រវឹង) និងបារីបន្ទាប់ពីបាននាំចូល ឬផលិតផលជាប់អាករក្នុងព្រះរាជាណាចក្រកម្ពុជា ។

### ៣.១.៣ បេសកកម្ម និងទស្សនៈវិស័យរបស់អាករពិសេស

#### ក.ទស្សនៈវិស័យ

អាករពិសេសជា ពន្ធប្រចាំខែដែលត្រូវបានគិតលើផលិតផលក្នុងស្រុក ផលិតផលនាំចូល និងសេវាកម្មមួយចំនួន ។ អ្នកជាប់ពន្ធក្នុងស្រុកដែលផលិតផ្គត់ផ្គង់ទំនិញឬសេវាកម្មទាំងនេះត្រូវទទួលខុសត្រូវចំពោះការបង់អាករប្រភេទនេះ ។

ចំពោះបារី និងស្រាបៀរគ្រប់ប្រភេទត្រូវជាប់អាករពិសេសក្នុងអត្រាខ្ពស់ជាងមុខទំនិញ និងសេវាផ្សេងៗដោយសារទំនិញទាំងបីមុខនេះមានផលប៉ះពាល់យ៉ាងខ្លាំងដល់អ្នកប្រើប្រាស់ ។

#### ខ.បេសកកម្ម

❖ សកម្មភាព

អាករពិសេសអនុវត្តនការប្រកាស និងការបង់ពន្ធដូចជា ៖

- អ្នកប្រើប្រាស់ទំនិញ ឬសេវា

**អ្នកប្រើប្រាស់ ឬសេវា**គឺជាអ្នកទទួលបន្ទុកបង់អាករពិសេសព្រោះវាគឺជាប្រភេទពន្ធដោយប្រយោលដែលអ្នកជាប់ពន្ធភាគច្រើនមិនបានដឹងខ្លួននោះទេ

- សហគ្រាស ឬអាជីវករ

  **ម្ចាស់សហគ្រាស ឬអាជីវករ**ជាភ្នាក់ងារកាត់ទុកប្រាក់ពន្ធពីការលក់ទំនិញ ឬផ្គត់ផ្គង់ទំនិញ ឬសេវា នោះពីអតិថិជន ឬអ្នកប្រើប្រាស់ហើយយកមកបង់ជូនរដ្ឋបាលសារពើពន្ធ ។

- អាករពិសេសត្រូវបង់តែមួយដងគត់ដោយបុគ្គលជាប់អាករពិសេស
- អាករពិសេសដល់កំណត់ត្រូវបង់ពន្ធនៅពេលផ្គត់ផ្គង់

  **ចំពោះទំនិញនៅពេលដែលចូលត្រូវបានចាត់ទុកថាបានលក់ ឬបានផ្គត់ផ្គង់**នៅពេលត្រូវបាននាំចូលមកក្នុងតំបន់ត្រួតពិនិត្យគយក្នុងព្រះរាជាណាចក្រកម្ពុជា

  **ចំពោះទំនិញផលិត និងសេវា ដែលបានផ្គត់ផ្គង់ក្នុងស្រុក**គឺជាពេលដែលអ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយបត្រ មុនពេលត្រូវចេញវិក្កយបត្រ ។ កាលបរិច្ឆេទបង់អាករ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ២០នៃខែបន្ទាប់ ។

### ៣.១.៤ រចនាសម្ព័ន្ធគ្រប់គ្រងរបស់អគ្គនាយកពន្ធដារ



- ឯកឧត្តម **ម៉ិញ បានកុសល** អគ្គនាយករង
- ឯកឧត្តម **កែន សម្បត្តិ** អគ្គនាយករង
- ឯកឧត្តម **ហេង សុខ ណាង** អគ្គនាយករង
- លោកជំទាវ **ម៉ុន នារី** អគ្គនាយិការង

**នាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ**

1. នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
2. នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក
3. នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ
4. នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ
5. នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
6. នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ
7. នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
8. នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យម
9. នាយកដ្ឋានសវនកម្មសហគ្រាស
10. សាលាជាតិពន្ធដារ
11. ទីចាត់ការពន្ធដាររាជធានីភ្នំពេញ

## ៣.២ ភាពខុសគ្នារវាងអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេស នៃអគ្គនាយកដ្ឋានពន្ធដារ

❖ **ភាពខុសគ្នារវាងអាករសម្រាប់បំភ្លឺសាធារណៈ**

១.អាករសម្រាប់បំភ្លឺសាធារណៈ ជាអាករមួយប្រភេទដែលកំណត់លើគ្រប់ដំណាក់កាល នៃការផ្គត់ផ្គង់សុរាមេរ័យ (គ្រឿងស្រវឹង) និងបារីក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាប្រយោជន៍ដល់ថវិកាថ្នាក់ក្រោមជាតិសម្រាប់បំភ្លឺសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា ។

២.អាករសម្រាប់បំភ្លឺសាធារណៈ ត្រូវអនុវត្តគ្រប់ដំណាក់នៃការផ្គត់ផ្គង់សុរាមេរ័យ(គ្រឿងស្រវឹង) និងបារី ។

៣.អាករសម្រាប់បំភ្លឺសាធារណៈត្រូវ កំណត់តាមអត្រា ៥% នៃមូលដ្ឋានគិតពន្ធ(ច្បាប់ថ្មី) ។

❖ **អាករពិសេសនៃអគ្គនាយកដ្ឋានពន្ធដារ**

១.អាករពិសេសគឺ ជាប្រភេទអាករដែលត្រូវបង់លើទំនិញ ឬសេវាកម្មជាក់លាក់ដែលរដ្ឋាភិបាលបានកំណត់ ។

២.អាករពិសេស ត្រូវអនុវត្តទៅលើសេវាលំហែកម្សាន្ត និងសេវាដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសក្នុង និងក្រៅប្រទេស ។

៣.អាករពិសេស ត្រូវបានកំណត់ទៅលើមុខទំនិញ និងសេវាមួយចំនួនដែលមានអត្រាដូចខាងក្រោម ៖

- សុរា ៣៥%
- ស្រាបៀរ ៣០%
- បារីគ្រប់ប្រភេទ ២០%

- បារីស៊ីហ្គា ២៥%
- ភេសជ្ជៈ ១០%
- ស៊ីម៉ងត៍គ្រប់ប្រភេទ ៥%
- សេវាដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសក្នុង និងក្រៅប្រទេស១០%
- សេវាលំហែកម្សាន្ត ១០%
- សេវាទូរគមនាគមន៍ក្នុង និងក្រៅប្រទេសមានអត្រា ៣% ។

**ក.លក្ខណៈអាករបំភ្លឺសាធារណៈ**

យោងតាមប្រកាសលេខ ៩៧៦ សហវ.ប្រក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកំណត់មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពាក្យ «អាករសម្រាប់បំភ្លឺសាធារណៈ» ត្រូវបានឱ្យនិយមន័យថាជាអាករមួយប្រភេទដែលត្រូវកំណត់លើគ្រប់ដំណាក់កាលនៃការផ្គត់ផ្គង់សុរាមេរ័យ និងបារីបន្ទាប់មកបាននាំចូល ឯផលិតផលជាប់អាករ ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាប្រយោជន៍ដល់ថវិកាថ្នាក់ក្រោមជាតិសម្រាប់បំភ្លឺសាធារណៈដែលពាក្យ «ផលិតផលជាប់អាករ» សំដៅដល់សុរាមេរ័យ និងបារី ។

ក្នុងន័យនេះ «សុរាមេរ័យ» សំដៅដល់ (១)ស្រាបៀរ (២)ស្រាទំពាំងបាយជូរស្រស់ រួមទាំងស្រាទំពាំងបាយជូរដែលមានបន្ថែមជាតិសុរា (៣)ស្រាវ៉ែមុត និងស្រាទំពាំងបាយជូរផ្សេងទៀតផ្សំពីរុក្ខជាតិ និងសារជាតិក្រអូប (៤)ភេសជ្ជៈមេរ័យផ្សេងទៀតលើកលែងតែទឹកត្នោតជូរ និងស្រាដែលផលិតក្នុងស្រុកជាលក្ខណៈគ្រួសារ (៥) អាល់កុលអេទីលិកសុទ្ធដែលមានកម្រិតជាតិសុរាក្នុងឯកតាចំណុះពី ៨០% នៃចំណុះ ឬលើសពីនេះ និងអាល់កុលអេទីលិក និងភេសជ្ជៈមានជាតិសុរាដែលបាត់បង់កម្រិតសុរាដើមរបស់វា និង (៦) អាល់កុលអេទិលិកបាត់បង់ជាតុសុទ្ធដែលមានកម្រិតជសតិសុរាក្នុងឯកតាចំណុះ ៨០% នៃចំណុះ និងភេសជ្ជៈមានជាតិសុរាភេសជ្ជៈស្រវឹងផ្សេងៗទៀតការរបៀបចំកែច្នៃសុរាផ្សំក្នុងប្រទេសដែលប្រើសម្រាប់ផលិតភេសជ្ជៈ ។ ចំណែកឯ«បារី» សំដៅដល់ផលិតផលសម្រាប់សម្រាប់ជក់គ្រប់ប្រភេទដែលមានផលិតឡើងពីថ្នាំជក់ រួមបញ្ចូលទាំងបារីអគ្គិសនីគ្រប់ប្រភេទផងដែរ ។




ច្បាប់តម្រូវអោយដាក់សារព្រមានជារូបភាព។ បារីដែលមិនគោរពច្បាប់ហៅថាបារីថ្លើមធំ!!!

ផ្អែកតាមការប្រកាសខាងលើនេះដដែលអ្នកដែលមានកាតព្វកិច្ចត្រូវបង់អាករសម្រាប់បំភ្លឺសាធារណៈ គឺជាអ្នកផលិតអ្នកនាំចូល និងអ្នកផ្គត់ផ្គង់បន្តនូវផលិតផលជាប់អាករ និងត្រូវបាត់នៅពេលផ្គត់ផ្គង់ ឬផ្គត់ផ្គង់បន្ត ។ បន្ថែមពីនេះអ្នកជាប់អាករត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់អាករសម្រាប់បំភ្លឺសាធារណៈជារៀងរាល់ខែយ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលផលិតផលត្រូវបានផ្គត់ផ្គង់ ។

**ខ.លក្ខណៈអាករពិសេស**

អាករពិសេសគឺជាប្រភេទអាករដែលត្រូវបង់លើទំនិញ ឬសេវាកម្មជាក់លាក់ដែលរដ្ឋាភិបាលកំណត់ដោយមានលក្ខណៈសម្បត្តិដូចខាងក្រោម ៖

1. អាករដែលគ្រប់គ្រងលើទំនិញ និងសេវាកម្មជាក់លាក់
   - អាករនេះអនុវត្តលើទំនិញ ឬសេវាកម្មដែលប្រទេសជាតិចង់គ្រប់គ្រងឬកាត់បន្ថយការប្រើប្រាស់ដូចជាប្រេងសាំង យានជំនិះ បរិក្ខារសេពគីមី និងសេវាកម្សាន្តជាក់លាក់ ។
2. បំពេញបែបបទការចូលប្រើប្រាស់ ឬការប្រើប្រាស់ទំនិញ ឬសេវាកម្ម
   - អាករនេះមានគោលបំណងជំរុញឲ្យប្រើប្រាស់តិចតួច ឬត្រូវចូលរួមបង់ថ្លៃអាករថែមលើទំនិញ និងសេវាកម្មដែលអាចបង្កឱ្យមានផលប៉ះពាល់ដល់សង្គម ។
3. មានអត្រាអាករដែលខុសប្លែកពីអាករផ្សេងៗ
   - អាករនេះអាចមានអត្រាដែលខុសគ្នាតាមប្រភេទទំនិញ ឬសេវាកម្ម ។ ជាទូទៅវាមានអត្រាខ្ពស់ជាងអាករផ្ទាល់លើប្រាក់ចំណូល ឬអាករផ្សេងៗ ។
4. ជាប្រភពចំណូលសំខាន់សម្រាប់រដ្ឋ
   - ព្រោះអាករពិសេសត្រូវបង់លើទំនិញ និងសេវាកម្មដែលមានតម្លៃខ្ពស់ ឬមានតំរូវការខ្ពស់នេះបណ្តាលឱ្យរដ្ឋអាចប្រមូលចំណូលបានច្រើនពីប្រភពនេះ ។
5. ជាមធ្យោបាយសម្រាប់គោលនយោបាយសង្គម និងបរិស្ថាន
   - អាករនេះអាចប្រើសម្រាប់ជំរុញឱ្យប្រជាជនបន្ថយការប្រើប្រាស់ទំនិញដែលអាចបង្កឱ្យមានផលប៉ះពាល់ដល់សុខភាព និងបរិស្ថានដូចជាសារជាតុគីមី បារី សារជាតុញៀន និងផលិតផលដែលបំពុលបរិស្ថាន ។
6. អាចមានលក្ខខណ្ឌឬការលើកលែង
   - នៅក្នុងករណីណាមួយជាក់លាក់អាករពិសេសអាចត្រូវបានលើកលែងសម្រាប់ទំនិញ ឬសេវាកម្មដែលមានអត្ថប្រយោជន៍សម្រាប់សង្គម ឬការនាំចេញដែលរដ្ឋចង់លើកកម្ពស់ ។

**៣.២.១ គោលបំណងនៃអាករបំភ្លឺសាធារណៈ និងអាករពិសេស**

- អនុវត្តចំពោះការផ្គត់ផ្គង់សុរាមេរ័យ ឬបារីបន្ទាប់ពីបាននាំចូល ឬផលិតក្នុងស្រុកពេលផ្គត់ផ្គង់ទំនិញសេវា
- ដើម្បីទប់ស្កាត់នឹងកាត់បន្ថយការប្រើប្រាស់ប្រភេទទំនិញដែលមានលក្ខណៈប៉ះពាល់ដល់សុខភាព
- ដើម្បីជាប្រយោជន៍ក្នុងការរកចំណូលដល់ថវិការរដ្ឋ

**ក.គោលបំណង់នៃអាករបំភ្លឺសាធារណៈ**

- ផ្តល់ប្រាក់ធនសម្រាប់ការតម្លើងនឹងថែទាំ
- ជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច

ខ.គោលបំណងនៃអាករពិសេស

- ដើម្បីគុណប្រយោជន៍ថវិកាសម្រាប់ថ្នាក់ជាតិ
- កាត់បន្ថយការប្រើប្រាស់ទំនិញដែលប៉ះពាល់សង្គម និងបរិស្ថាន
- គ្រប់គ្រងវិស័យនិងទីផ្សារ
- បង្កើតភាពសមហេតុសមផលក្នុងសង្គម

**៣.២.២ បុគ្គលជាប់អាករ**

បុគ្គលជាប់អាករ គឺជាបុគ្គលដែលមានកាតព្វកិច្ចត្រូវបង់ពន្ធជូនរដ្ឋ(តាមមាត្រា ៨៨ នៃច្បាប់ស្តីពីសារពើពន្ធ)។ ជាទូទៅបុគ្គលជាប់ពន្ធសំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់រដ្ឋាភិបាល និងរាល់សកម្មភាពផ្សេងៗដែលទទួលស្គាល់ជាសាធារណៈទៅតាមការកំណត់របស់អង្គភាពពន្ធដារ ។ បុគ្គលជាប់ពន្ធត្រូវមានកាតព្វកិច្ចប្រមូលពន្ធជំនួសរដ្ឋពីបុគ្គលទទួលរងពន្ធ និងបុគ្គលជាប់ពន្ធនេះក៏ត្រូវទទួលរងពន្ធដោយផ្ទាល់ខ្លួនឯងផងដែរ ។ បុគ្គលទទួលរងពន្ធ ជាបុគ្គលដែលមានចំណូលហើយទទួលការជះឥទ្ធិពលដោយប្រយោលពីពន្ធ ។ បុគ្គលនេះត្រូវបានរដ្ឋប្រមូលយកចំណូលតាមរយៈពន្ធដោយប្រយោល ឬដោយផ្ទាល់ក្តី ។

❖ **អាករពិសេស**

**ក.បុគ្គលជាប់អាករពិសេស**

ប្រភេទបុគ្គលជាប់អាករពិសេស

១. អ្នកផលិតទំនិញក្នុងស្រុក

ក្រុមហ៊ុន ឬអង្គភាពណាមួយដែលផលិតទំនិញដែលជាប់អាករពិសេសនៅក្នុងប្រទេសត្រូវបង់អាករនេះមានដូចជា ៖

- រោងចក្រផលិតស្រា ស្រាបៀរ និងសុរាមេរ័យ ផ្សេងៗ
- រោងចក្រផលិតបារី
- ផលិតផលប្រេងឥន្ធនៈ ឬទំនិញប្រើប្រាស់ថាមពលខ្ពស់

២. អ្នកនាំចូល

- អ្នកនាំចូលទំនិញដែលជាប់អាករពិសេសត្រូវបង់អាករនេះដើម្បីនាំចូល

**ឧទាហរណ៍៖**

- អ្នកនាំចូលស្រា ស្រាបៀរ និងបារីពីក្រៅប្រទេស

៣.អ្នកផ្តល់សេវាកម្មជាប់អាករពិសេស

មានសេវាកម្មមួយចំនួនវចដែលត្រូវបង់អាករពិសេសដូចជា ៖

- សេវាកម្មកាស៊ីណូ ល្បែងស៊ីសង អ្នកសេវាកម្មក្លឹបរាត្រី និងកន្លែងកម្សាន្តពិសេស ។

**ខ.ទំនិញជាប់អាករពិសេស**

ទំនិញដែលជាប់អាករពិសេសមានដូចជា

១. ផលិតផលតេលសិលា

- ប្រេងសាំងស៊ុបព័រ
- ប្រេងសាំងធម្មតា
- ប្រេងម៉ាស៊ូត
- ប្រេងរំអិលគ្រប់ប្រភេទ

២.ភេសជ្ជៈ

- ស្រាគ្រប់ប្រភេទ
- ស្រាបៀរគ្រប់ប្រភេទ
- ភេសជ្ជៈគ្មានជាតិសុរា
- ភេសជ្ជៈមេវ័យផ្សេងទៀត ។

ភេសជ្ជៈគ្មានជាតិសុរា សំដៅដល់ទឹកដែលមានជាតិឧស្ម័ន ឬដាក់ជាតិស្ករ ឬដាក់រសជាតិផ្អែមផ្សេងទៀត ដែលគ្មានជាតិសុរាលើកលែងតែទឹក និងទឹកមីណេរ៉ាល់ ទឹកដោះគោ សំដៅដល់ផលិតផលដែលផលិតចេញពី ផ្លែឈើ ឬបន្លែសុទសាធពីធម្មជាតិដែលគ្មានលក្ខខណ្ឌទាំងពីរដូចជា គ្មានការកែច្នៃរក្សាគុណភាព និងវេចខ្ចប់ តាមរូបភាពសិប្បកម្ម ឬឧស្សាហកម្ម និងគ្មានសារធាតុបន្ថែមរសជាតិ ឬក្លិន ឬពណ៌ ។

- បារី-ស៊ីហ្គាគ្រប់ប្រភេទ
- ស៊ីម៉ង់ត៍
- កាណូតកម្សាន្ត
- ផលិតផលកញ្ចក់ជាគ្រឿងសំណង់
- រថយន្ត ទោចក្រយាន និងគ្រឿងបន្លាស់
- ផលិតផលគ្រឿងសម្អាង
- ផលិតផលប្លាស្ទិច...។

**គ.សេវាជាប់អាករពិសេស**

អាករពិសេសលើសេវា អនុវត្តទៅលើ

- សេវាដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសក្នុង និងក្រៅប្រទេស
  - ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស ត្រូវប្រមូលលើមូលដ្ឋានតម្លៃដែលបានចុះក្នុងសំបុត្រយន្តហោះដែលបានចេញ ឬលក់ឲអ្នកដំណើរក្នុងប្រទេស ។ ចំពោះសំបុត្រទៅ-មក សម្រាប់ធ្វើដំណើរចេញពីកម្ពុជានិងត្រឡប់មកកម្ពុជាវិញត្រូវប្រមូលលើ50% នៃថ្លៃមូលដ្ឋាននៃសំបុត្រនោះ ។
- សេវាទូរគមនាគមន៍ក្នុង និងក្រៅប្រទេស
- សេវាលំហែកម្សាន្ត
  - ការប្រគុំតន្ត្រី ការចាក់ភ្លេង សម្តែងឈុតឆាក ឬកាយវិការមានលក្ខណៈជាសកម្មភាពនៅក្នុងរង្គសាល , ខារ៉ាអូខេ, ទីកន្លែងសាធារណៈឬកន្លែងណាមួយ
  - ចំពោះសណ្ឋាគារ ឬភោជនីយដ្ឋានដែលមានក្នុងការប្រគុំតន្ត្រី ការសម្តែងឈុតឆាក ឬកាយវិការមានលក្ខណៈផ្សារភ្ជាប់នឹង សកម្មភាពសណ្ឋាគារ ឬភោជនីយដ្ឋាន

- ម៉ាស្សា ប្រណាំងរថយន្ត karting ប្រណាំងម៉ូតូ ស្នូកឃ័រ Bowling ហ្គេមគ្រប់ប្រភេទ និងវាយកូនគោល។

**ឃ. ការលើកលែងអាករពិសេស**

ត្រូវបានលើកលែងអាករពិសេសចំពោះការនាំចូលរបស់បុគ្គលដែលគ្មានកាតព្វកិច្ចចុះបញ្ជី

- បារី ២០០ដើម
- ស៊ីហ្គា ៥០ដើម
- ស្រាចំណុះ ២លីត្រ... ។

❖ អាករសម្រាប់បំភ្លឺសាធារណៈ

**ក.បុគ្គលជាប់អាករបំភ្លឺសាធារណៈ**

ប្រភេទបុគ្គលជាប់អាករបំភ្លឺសាធារណៈ

១. ចំពោះអ្នកផលិត និងអ្នកនាំដែលត្រូវបានកត់ត្រាលើវិក្កយបត្ររួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម និងអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង ។

២. ចំពោះអ្នកផ្គត់ផ្គង់បន្ត មូលដ្ឋានគិតអាករស្មើរ២០%នៃថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាលើវិក្កយបត្ររួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម និងអាករបំភ្លឺសាធារណៈខ្លួនឯង ។

**ខ.ទំនិញជាប់អាករបំភ្លឺសាធារណៈ**

- ស្រាទំពាំងបាយជូរស្រស់ផ្សេងទៀតផ្សំពីរុក្ខជាតិ និងសារជាតិក្រអូបភេសជ្ជៈមេរ័យផ្សេងទៀតលើកលែងទឹកត្នោតជូរ និងស្រាស
- អាកុលអេទិលិកសុទ្ធដែលមានកម្រិតសារជាតិសុរាក្នុងឯកតាចំណុះពី ៨០% នៃចំណុះ ឬលើសពីនេះអាកុលហើយ នឹងភេសជ្ជៈមានជាតិសុរាដែលបាត់បង់កម្រិតជាតិសុរាដើមរបស់វា
- អាកុលបាត់បង់ជាតុសុទ្ធដែលមានកម្រិតជាតិសុរាឯកតាចំណុះពី ៨០% នៃចំណុះ និងភេសជ្ជៈមានជាតិសុរា ភេសជ្ជៈស្រវឹងផ្សេងៗទៀត ការរបៀបចំការឆ្នៃសុរាផ្សំក្នុងប្រភេទដែលប្រើសម្រាប់ផលិតភេសជ្ជៈ ។

**គ. កម្មវត្ថុនៃអាករសម្រាប់បំភ្លឺសាធារណៈ**

អាករបំភ្លឺសាធារណៈត្រូវអនុវត្តលើការផ្គត់ផ្គង់ផលិតផលសុរា មេរ័យ ឬថ្នាំជក់ ។ ប្រាក់ចំណូលនេះសម្រាប់ជាប្រយោជន៍ថ្នាក់ខេត្ត-ក្រុង សម្រាប់ចំណាយលើការបំភ្លឺសាធារណៈ

**ឃ.ការលើកលែងអាករ**

អាករបំភ្លឺសាធារណៈត្រូវបានលើកលែងចំពោះ

- ស្រាដែល ផលិតលក្ខណៈគ្រួសារ
- ទឹកត្នោតជូរ
- ថ្នាំជក់ ជាវត្ថុធាតុដើម ។

## ៣.៣ និតិវិធីនៃការប្រមូលពន្ធអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេស នៃអគ្គនាយកដ្ឋានពន្ធដារ

### ៣.៣.១ មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ និងអាករពិសេស

**ក.មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ**

មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ ត្រូវបានកំណត់ដូចខាងក្រោម ៖

១.ចំពោះអ្នកផលិត និងអ្នកនាំចូលមូលដ្ឋានគិតអាករគឺជាថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាលើវិក្កយបត្ររួមបញ្ចូលទាំងពន្ធអាករនានាលើកលែងតែអាករលើតម្លៃបន្ថែម និងអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង ។

២.ចំពោះអ្នកផ្គត់ផ្គង់បន្តមូលដ្ឋានគិតអាករស្មើនឹង២០ភាគរយនៃថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាវិក្កយបត្ររួមបញ្ចូលទាំងពន្ធអាករនានាលើកលែងតែអាករលើតម្លៃបន្ថែម និងអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង ។

ដោយយោងតាមប្រកាសអន្តរក្រសួងលេខ១៧៥ សហវ.ពដ.ប្រក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០២ស្តីពីការគ្រប់គ្រង និងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈរបស់ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាករសម្រាប់បំភ្លឺសាធារណៈត្រូវបានកំណត់តាមអត្រា ៣% (ច្បាប់ចាស់) ។

បន្ថែមពីនេះផងដែរ កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ ៤៨៦ អនក្រ.បក ស្តីពីអាករសម្រាប់បំភ្លឺសាធារណៈដោយកំណត់អាករសម្រាប់បំភ្លឺសាធារណៈតាមអត្រា ៥% (ច្បាប់ថ្មី) ដែលមានសុពលភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ តទៅ ។

សរុបសេចក្តីមកអាករបំភ្លឺសាធារណៈ ជាអាករមួយប្រភេទដែលបង្កើតឡើងដើម្បីជាប្រយោជន៍ដល់ថវិកាថ្នាក់ក្រោមជាតិសម្រាប់បំភ្លឺផ្លូវសាធារណៈទូទាំងប្រទេស ។ អាករប្រភេទនេះត្រូវបានកំណត់លើគ្រប់ដំណាក់កាលនៃការផ្គត់ផ្គង់សុរាមេរ័យ (គ្រឿងស្រវឹង) និងបារី បន្ទាប់ពីបាននាំចូល ឬផលិតផលជាប់អាករក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ខ.មូលដ្ឋានគិតអាករពិសេស**

- សម្រាប់ផលិតផលក្នុងស្រុកត្រូវគណនាយកមូលដ្ឋានពន្ធដោយផ្អែកទៅលើតម្លៃលក់ ដែលតម្លៃលក់នោះកំណត់យក ៩០ % នៃតម្លៃលក់មិនរាប់បញ្ចូលអាករលើតម្លៃបន្ថែម ( VAT ) ។
- សម្រាប់ផលិតផលនាំចូលត្រូវគណនាយកមូលដ្ឋានពន្ធដោយផ្អែកទៅលើថ្លៃទំនិញបូកបញ្ចូលពន្ធគយថ្លៃធានារ៉ាប់រង និងដឹកជញ្ជូនប៉ុន្តែមិនបូក VAT ។
- សម្រាប់សេវាបំពេញលំហែកម្សាន្តត្រូវគណនាយកមូលដ្ឋានពន្ធដោយផ្អែកលើថ្លៃទំនិញ និងសេវាកត់ត្រាលើវិក្កយបត្រដោយមិនទាន់គិតបញ្ចូលអាករពិសេសខ្លួនឯង និងអាករលើតម្លៃបន្ថែមទេ ។

### ៣.៣.២ វិធីសាស្ត្រនៃការប្រមូលអាករបំភ្លឺសាធារណៈ និងអាករពិសេស

**ក. វិធីសាស្ត្រនៃការប្រមូលអាករបំភ្លឺសាធារណៈ**

មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈត្រូវបានកំណត់ដូចខាងក្រោម ៖

- **ចំពោះអ្នកផលិតនិងអ្នកនាំចូល** មូលដ្ឋានគិតអាករគឺជាថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាលើវិក្កយបត្ររួមបញ្ចូលទាំងពន្ធអាករនានារៀវលែងតែអាករលើតម្លៃបន្ថែម និងអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង ។

**រូបមន្ត**

សម្រាប់វិក្កយបត្រអាករ-អ្នកផលិត និងអ្នកនាំចូល
មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ = តម្លៃសរុបលើវិក្កយបត្រមិនរួមអាករ + អាករពិសេស

សម្រាប់វិក្កយបត្រធម្មតា
មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ = តម្លៃសរុបលើវិក្កយបត្ររួមអាករ ៖ អតប ៖ អាករបំភ្លឺសាធារណៈខ្លួនឯង

អាករបំភ្លឺសាធារណៈត្រូវបង់ = មូលដ្ឋានគិតអាករ x អត្រាអាករ

- **ចំពោះអ្នកផ្គត់ផ្គង់បន្ត** មូលដ្ឋានគិតអាករស្មើនឹង២០ភាគរយនៃថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាលើវិក្កយបត្ររួមបញ្ចូលទាំងពន្ធអាករនានាលើកលែងតែអាករលើតម្លៃបន្ថែម និងអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង ។

**រូបមន្ត**

សម្រាប់វិក្កយបត្រអាករ-អ្នកផ្គត់ផ្គង់បន្ត (សេវាកម្សាន្ត )
មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ = ( តម្លៃសរុបលើវិក្កយបត្រមិនរួមអាករ + អាករពិសេស ) x ២០%

សម្រាប់វិក្កយបត្រអាករ-អ្នកផ្គត់ផ្គង់បន្ត
មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ = តម្លៃសរុបលើវិក្កយបត្រមិនរួមអាករ x ២០%

សម្រាប់វិក្កយបត្រធម្មតា-អ្នកផ្គត់ផ្គង់បន្ត
មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ = (តម្លៃសរុបលើវិក្កយបត្ររួមអាករ ៖ អាករ ៖ អាករបំភ្លឺសាធារណៈខ្លួនឯ) x ២០%

អាករបំភ្លឺសាធារណៈត្រូវបង់ = មូលដ្ឋានគិតអាករ x អត្រាអាករ

អត្រាអាករសម្រាប់បំភ្លឺសាធារណៈ គឺ ៣% (ច្បាប់ចាស់) ៥% (ច្បាប់ថ្មី)

❖ ការគណនាអាករសម្រាប់បំភ្លឺសាធារណៈ

- **ការគណនាអាករសម្រាប់បំភ្លឺសាធារណៈសម្រាប់អ្នកផលិត**

| ល.រ N⁰ | បរិយាយ Description | តម្លៃមិនរួមអាករ Amount exclude tax | អាករពិសេស Specific Tax | អាករបំភ្លឺ Public for Lighting tax | អតប VAT | ថ្លៃរួមអាករ Amount include tax |
|---|---|---|---|---|---|---|
| | A | B | C=(B*90%)*80% | D=(B+C)*3% | E=(B+C+D)*10% | F=(B+C+D+E) |
| 1 | ស្រា | 1,000,000 | 315,000 | 39,450 | 135,445 | 1,489,895 |
| 2 | ស្រាបៀរ | 1,500,000 | 405,000 | 57,150 | 155,715 | 2,117,865 |
| 3 | បារី | 500,000 | 90,000 | 17,700 | 51,770 | 659,470 |
| សរុបរួម | | 3,000,000 | | 114,300 | 342,930 | 4,267,230 |

- **ការគណនាអាករសម្រាប់បំភ្លឺសាធារណៈសម្រាប់អ្នកនាំចូល**

| ល.រ N⁰ | បរិយាយ Description | តម្លៃមិនរួមអាករ Amount exclude tax | អាករបំភ្លឺ Public for Lighting tax | អតប VAT | ថ្លៃរួមអាករ Amount include tax |
|---|---|---|---|---|---|
| | A | B | D=B*3% | E= (B+C) 10% | F=(B+C+D+E) |
| 1 | ស្រា | 1,000,000 | 30,000 | 103,000 | 1,133,000 |
| 2 | ស្រាបៀរ | 1,500,000 | 45,000 | 154,500 | 1,699,500 |
| 3 | បារី | 500,000 | 15,000 | 51,500 | 566,500 |
| សរុបរួម | | 3,000,000 | 90,000 | 309,000 | 3,399,000 |

❖ ការប្រកាស និងការបង់ប្រាក់អាករ

**អនុវត្តដូចវិធាននៃការផ្គត់ផ្គង់នៃអាករលើតម្លៃបន្ថែមពេលផ្គត់ផ្គង់**

- អ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយបត្រ ឬពេលបានចេញវិក្កយបត្រ
- ការដកហូតទំនិញប្រើប្រាស់ខ្លួនឯង ៖ ពេលដែលដកទំនិញយកទៅប្រើសប្រាស់
- អំណោយ ៖ ពេលដែលទំនិញត្រូវបានប្រគល់ឱ្យ
- កិច្ចសន្យា ៖ ពេលទំនិញត្រូវប្រគល់ ។

**ខ វិធីសាស្ត្រនៃការប្រមូលអាករពិសេស**

មូលដ្ឋានគិតអាករពិសេសត្រូវបានកំណត់ដូចខាងក្រោម ៖

- **ចំពោះទំនិញផលិតក្នុងស្រុក** មូលដ្ឋានសម្រាប់គិតអាករពិសេសលើមុខទំនិញមួយចំនួន ដែលផលិតក្នុងស្រុកដូចជា៖ ស្រាបៀរ ស្រា បារី និងបារីស៊ីហ្គាគ្រប់ប្រភេទ ភេសជ្ជៈគ្មានជាតិ សុរា និងមុខទំនិញជាប់អាករពិសេសដទៃទៀត ត្រូវកំណត់ស្មើនឹង៩០ភាគរយ នៃតម្លៃផ្គត់ផ្គង់ ដែលបានកត់ត្រាក្នុងវិក្កយបត្រឱ្យទៅអតិថិជន ដោយមិនរួមបញ្ចូលនូវអាករលើតម្លៃបន្ថែម អាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេសខ្លួនឯង។

រូបមន្ត

សម្រាប់វិក្កយបត្រអាករ
មូលដ្ឋានគិតអាករពិសេស = តម្លៃសរុបលើវិក្កយបត្រមិនរួមអាករ x ៩០%

សម្រាប់វិក្កយបត្រធម្មតា
មូលដ្ឋានគិតអាករពិសេស = តម្លៃសរុបលើវិក្កយបត្ររួមអាករ ៖ អតប ៖ អាករបំភ្លឺ (បើមាន) ៖ អាករពិសេសខ្លួន

អាករពិសេសត្រូវបង់ = មូលដ្ឋានគិតអាករ x អត្រាអាករ

- **ចំពោះសេវាបំពេញលំហែកម្សាន្ត** មូលដ្ឋានគិតអាករពិសេសលើសេវាលំហែកម្សាន្ត គឺជាថ្លៃ ទំនិញ និង សេវាកត់ត្រាលើវិក្កយបត្រដោយមិនទាន់គិតបញ្ចូលអាករពិសេសខ្លួនឯងនិងអាករ លើតម្លៃបន្ថែម ។

រូបមន្ត

សម្រាប់វិក្កយបត្រអាករ
មូលដ្ឋានគិតអាករពិសេស = តម្លៃសរុបលើវិក្កយបត្រមិនរួមអាករ (សេវា + ទំនិញ)

សម្រាប់វិក្កយបត្រធម្មតា
មូលដ្ឋានគិតអាករពិសេស = តម្លៃសរុបលើវិក្កយបត្រមិនរួមអាករ ៖ អតប ៖ អាករពិសេសខ្លួនឯង

អាករពិសេសត្រូវបង់ = មូលដ្ឋានគិតអាករ x អត្រាអាករ

- **ចំពោះទំនិញនាំចូល** មូលដ្ឋានសម្រាប់គិតអាករពិសេសចំពោះទំនិញនាំចូល គឺតម្លៃគិតពន្ធ គយដែល កំណត់តាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីគយ ដោយរួមបញ្ចូលនូវពន្ធនាំចូល ។

រូបមន្ត

សម្រាប់វិក្កយបត្រអាករ នាំចូល
មូលដ្ឋានគិតអាករពិសេស = (Cost Insurance and Freight (CIF) + ពន្ធនាំចូល

អាករពិសេសត្រូវបង់ = មូលដ្ឋានគិតអាករ x អត្រាអាករ

❖ ការគណនាអាករពិសេសលើទំនិញ និងសេវាមួយចំនួន

- ការគណនាអាករពិសេសលើស្រា

| ល.រ N0 | បរិយាយ Description | តម្លៃមិនរួមអាករ Amount exclude tax | អាករពិសេស Specific Tax | អាករបំភ្លឺ Public for Lighting tax | អតប VAT | ថ្លៃរួមអាករ Amount include tax |
|---|---|---|---|---|---|---|
| | A | B | C=(B*90%)*35% | D=(B+C)*3% | E=(B+C+D)*10% | F=(B+C+D+E) |
| 1 | ស្រា | 40,000 | 12,600 | 1,578 | 5,418 | 59,596 |
| សរុបរួម | | 40,000 | 12,600 | 1,578 | 5,418 | 59,596 |

- ការគណនាអាករពិសេសលើស្រាបៀរ

| ល.រ N0 | បរិយាយ Description | តម្លៃមិនរួមអាករ Amount exclude tax | អាករពិសេស Specific Tax | អាករបំភ្លឺ Public for Lighting tax | អតប VAT | ថ្លៃរួមអាករ Amount include tax |
|---|---|---|---|---|---|---|
| | A | B | C=(B*90%)*30% | D=(B+C)*3% | E=(B+C+D)*10% | F=(B+C+D+E) |
| 1 | ស្រាបៀរ | 2,000,000 | 540,000 | 76,200 | 261,000 | 2,877,820 |
| សរុបរួម | | 2,000,000 | 540,000 | 76,200 | 261,000 | 2,877,820 |

❖ មូលដ្ឋានគិតអាករ អត្រាអាករ និងការគណនាអាករ

- ការគណនាអាករពិសេសលើបារី

| ល.រ N0 | បរិយាយ Description | តម្លៃមិនរួមអាករ Amount exclude tax | អាករពិសេស Specific Tax | អាករបំភ្លឺ Public for Lighting tax | អតប VAT | ថ្លៃរួមអាករ Amount include tax |
|---|---|---|---|---|---|---|
| | A | B | C=(B*90%)*20% | D=(B+C)*3% | E=(B+C+D)*10% | F=(B+C+D+E) |
| 1 | បារី | 1,000,000 | 180,000 | 35,400 | 121,540 | 1,336,940 |
| សរុបរួម | | 1,000,000 | 180,000 | 35,400 | 121,540 | 1,336,940 |

- ការគណនាអាករពិសេសលើភេសជ្ជៈគ្មានជាតិស្រា

| ល.រ N0 | បរិយាយ Description | តម្លៃមិនរួមអាករ Amount exclude tax | អាករពិសេស Specific Tax | អាករបំភ្លឺ Public for Lighting tax | អតប VAT | ថ្លៃរួមអាករ Amount include tax |
|---|---|---|---|---|---|---|
| | A | B | C=(B*90%)*10% | D=(B+C) *3% | E=(B+C+D) *10% | F=(B+C+D+E) |
| 1 | ទឹកក្រូចកំប៉ុង | 900,000 | 81,000 | | 98,000 | 1,079,100 |
| សរុបរួម | | 900,000 | 81,000 | | 98,000 | 1,079,100 |

❖ ការប្រកាសពន្ធ និងការបង់ពន្ធ

- អាករពិសេសត្រូវបង់តែមួយដងគត់ដោយបុគ្គលជាប់អាករពិសេស
- អាករពិសេសត្រូវដល់កំណត់ត្រូវបង់នៅពេលផ្គត់ផ្គង់

- ចំពោះទំនិញនាំចូល ត្រូវចាត់ទុកថាបានផ្គត់ផ្គង់នៅពេលបាននាំចូលមកក្នុងតំបន់ត្រួតពិនិត្យគយក្នុងព្រះរាជាណាចក្រកម្ពុជា
- ចំពោះទំនិញផលិត និងសេវាដែលផ្គត់ផ្គង់ក្នុងស្រុកគឺជាពេលដែល អ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយបត្រ ឬជាពេលដែលអ្នកផ្គត់ផ្គង់បានចេញវិក្កយបត្រ ។

កាលបរិច្ឆេទបង់អាករ យ៉ាងយឺតបំផុតត្រឹមថ្ងៃ២០ នៃខែបន្ទាប់ ។

**៣.៣.៣ ទំនិញដែលលើកលែងពន្ធ និងអាករ**

អនុលោមតាម បញ្ញត្តិមាត្រា២៦ នៃច្បាប់ស្តីពីគយជាធរមានការលើកលែងពន្ធ និងអាករត្រូវបានផ្តល់ជូនចំពោះទំនិញ និងអ្នកនាំចូលដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម ៖

- ទំនិញសម្រាប់បេសកកម្មការទូត ឬបេសកកម្មកុងស៊ុលបរទេសអង្គការអន្តរជាតិ និងភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលផ្សេងទៀតដើម្បីប្រើប្រាស់ក្នុងការិយកិច្ចនៃមុខងារជាផ្លូវការដោយមានការបញ្ជាក់ពីប្រធានបេសកកម្ម ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ទំនិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិកផ្លូវការនៃបេសកកម្ម និងអង្គការដូចបានរៀបរាប់នៅក្នុងលក្ខខណ្ឌនៃប្រការនេះ ។ ការអនុវត្តនូវវាក្យខណ្ឌនេះ និងលក្ខខណ្ឌនៃប្រការនេះត្រូវផ្អែកលើគោលការណ៍ច្បាប់អន្តរជាតិ និងគោលការណ៍បដិការរវាងរដ្ឋាភិបាលពាក់ព័ន្ធ
- ទំនិញមានដើមកំណើតកម្ពុជា ឬទំនិញនាំចូលដែលបានបង់ពន្ធ និងអាកររួចដែលចេញពីដែនគយហើយត្រូវនាំចូលត្រឡប់ពីបរទេសមកវិញដោយពុំមានការបង្កើនតម្លៃ
- ទំនិញដែលបានត្រូវលើកលែងពន្ធ និងអាករក្រោមបញ្ញត្តិនៃច្បាប់ផ្សេងទៀតរបស់ព្រះរាជាណាចក្រកម្ពុជា
- ទំនិញជាអំណោយសម្រាប់មនុស្សធម៌ ទំនិញសម្រាប់ការស្រាវជ្រាវ និងគោលបំណងវិទ្យាសាស្ត្រ ទំនិញគំរូ និងទំនិញតាំងពិព័រណ៍ដែលគ្មានតម្លៃពាណិជ្ជកម្មឈូសដែលមានសាកសពមនុស្ស
- ទំនិញនាំចូលដែលមានតម្លៃ និងបរិមាណច្បាស់លាស់មួយចំនួនតាមការកំណត់របស់អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាដែលនាំចូលដោយអ្នកដំណើរអ្នកបម្រើការតាមមធ្យោបាយដឹកជញ្ជូន និងជនទាំងឡាយដែលឆ្លងកាត់ព្រំដែន
- ទំនិញដែលចូលក្នុងដែនគយសម្រាប់ឆ្លងកាត់ ឬផ្ទេរមធ្យោបាយដឹកជញ្ជូន
- សម្ភារៈប្រើប្រាស់ក្នុងផ្ទះ សម្ភារប្រើប្រាស់ផ្ទាល់ខ្លួន និងទ្រព្យសម្បត្តិផ្សេងទៀតលើកលែងតែយានយន្តដែលនាំចូលមកដោយបុគ្គលដែលផ្លាស់ប្តូរទីលំនៅស្ថានមកកម្ពុជាក្នុងបរិមាណដែលត្រូវបានកំណត់ដោយអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- បរិក្ខារឧស្សាហកម្ម និងសម្ភារៈផ្សេងទៀតដែលជាតម្រូវការសម្រាប់ប្រតិបត្តិការ និងការថែរក្សាបរិក្ខារ ទាំងនេះដែលប្រើប្រាស់នៅក្នុងសមុទ្រសម្រាប់ការរុករក និងទាញយកផលិតផលតេលសិលា និងសារធាតុខនិជ និងសរីរាង្គផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ទំនិញផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

❖ បុគ្គលដែលនាំចូលទំនិញដូចខាងលើត្រូវផ្តល់នូវឯកសារភស្តុតាងដល់រដ្ឋបាលគយថាទំនិញមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលបានការលើកលែងពន្ធ និងអាករ ។

❖ អង្គការនានា និងបុគ្គលដែលមានបំណងស្នើសុំការលើកលែងពន្ធ និងអាករលើទំនិញនាំចូលក្រោមបញ្ញត្តិកថាខណ្ឌ១ និងកថាខណ្ឌ ២ ខាងលើត្រូវមានការអនុញ្ញាតជាមុនពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិស្របតាមនីតិវិធីជាធរមាន ។

❖ បុគ្គលដែលមានបំណងនាំចូលនូវទំនិញក្រោមបញ្ញត្តិនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តតាមនីតិវិធី និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។

❖ ការលើកលែងជាភាគនូវពន្ធ និងអាករនាំចូលត្រូវបានផ្តល់ចំពោះមុខទំនិញ និងអ្នកនាំចូលមួយចំនួនស្របតាមបញ្ញត្តិមាត្រា ២៧ នៃច្បាប់ស្តីពីគយជាធរមាន ។ ទំនិញដែលត្រូវបានលើកលែងជាភាគនូវពន្ធ និងអាករនាំចូលមានដូចខាងក្រោម ៖

- ទំនិញ និងសម្ភារៈដែលត្រូវបានលើកលែងជាភាគនូវពន្ធ និងអាករនាំចូលក្រោមបញ្ញត្តិនៃច្បាប់ណាមួយជាធរមាន
- ពូជដំណាំនិងពូជសត្វសម្រាប់កសិកម្ម
- ទំនិញដែល នឹងត្រូវទទួលការជួសជុលការកែច្នៃ ឬពិសោធន៍
- ទំនិញដែលបាននាំចូលវិញតាមសភាពដើម
- ទំនិញដែលនាំចូលមកដោយរដ្ឋាភិបាលដើម្បីជាប្រយោជន៍ដល់សាធារណៈ និងទំនិញនាំចូលសម្រាប់របបប្រវេសន៍កាលិក
- ទំនិញផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បុគ្គលដែលនាំចូលទំនិញក្រោមបញ្ញត្តិនៃប្រការនេះត្រូវផ្តល់នូវឯកសារជាភស្តុតាងដល់រដ្ឋបាលគយថាទំនិញមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលបាននៅការលើកលែងជាភាគនូវពន្ធ និងអាករ ។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

បន្ទាប់ពីបានសិក្សាស្រាវជ្រាវកន្លងមក ទៅលើការប្រមូលអាករបំភ្លឺសាធារណៈ និងអាករពិសេសរបស់អគ្គនាយកដ្ឋានពន្ធដារ ក្រុមនាងខ្ញុំបានវិភាគឃើញទៅលើចំណុចខ្លាំងមួយចំនួនមានដូចជា ៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

បន្ទាប់ពីបានធ្វើការស្រាវជ្រាវកន្លងមកទៅភាពខុសគ្នារវាអាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេសនៃអគ្គនាយកដ្ឋានពន្ធដាររួចមកក្រុមនាងខ្ញុំឃើញមានភាពវិជ្ជាមានដូចជា ៖

- ចូលរួមក្នុងការប្រមូលប្រាក់សម្រាប់រដ្ឋ និងផ្តល់សេវាកម្មសាធារណៈដូចជាសេវាកម្មសុខាភិបាល
- ឱ្យប្រជាជនមានការយល់ដឹង និងចេះពីការចំណាយសាធារណៈ
- អនុវត្តលើទំនិញ និងសេវាកម្មដែលប្រទេសជាតិចង់លុបបំបាត់ផលិតផលប្រេងសាំង បរិក្ខារសេពគីមី និងសេវាកម្សាន្ត
- ជួយឱ្យបញ្ហាសាធារណៈត្រូវបានដោះស្រាយដោយមានការយល់ដឹងច្បាស់ពីមនុស្សក្នុងសង្គមទាំងអស់
- កាត់បន្ថយការប្រើប្រាស់ទំនិញដែលមានលក្ខណៈប៉ះពាល់ដល់សុខភាព បរិស្ថាន និងសង្គម
- លើកកម្ពស់ទៅលើការជំរុញសង្គមក្នុងការចូលរួម និងការយល់ដឹងអំពីប្រព័ន្ធនានា ដូចជាការសិក្សា បញ្ហាសង្គម ឬការអភិវឌ្ឍន៍សេដ្ឋកិច្ច
- ធ្វើអោយការប្រមូលពន្ធមានការកើនឡើង ក្នុងការជួយធ្វើអោយប្រទេសជាតិមានការរីកចម្រើន និងការបង្កើតកម្មវិធីអប់រំសាធារណៈផ្សេងៗ
- អគ្គនាយកដ្ឋានពន្ធដារមានច្បាប់ស្ដីពីការគ្រប់គ្រង និងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈច្បាស់លាស់ដែលអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ
- ចំពោះទំនិញនាំចូល ត្រូវចាត់ទុកថាបានផ្គត់ផ្គង់នៅពេលបាននាំចូលមកក្នុងតំបន់ត្រួតពិនិត្យគយក្នុងព្រះរាជាណាចក្រកម្ពុជា
- សម្រាប់ផលិតផលក្នុងស្រុកត្រូវគណនាយកមូលដ្ឋានពន្ធដោយផ្អែកទៅលើតម្លៃលក់ ដែលតម្លៃលក់នោះកំណត់យក ៩០ % នៃតម្លៃលក់មិនរាប់បញ្ចូលអាករលើតម្លៃបន្ថែម
- ដើម្បីទប់ស្កាត់នឹងកាត់បន្ថយការប្រើប្រាស់ប្រភេទទំនិញដែលមានលក្ខណៈប៉ះពាល់ដល់សុខភាព

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទន្ទឹមនឹងភាពវិជ្ជមានដែលលើកឡើងខាងលើ តាមរយៈការស្រាវជ្រាវរបស់ក្រុមនាងខ្ញុំក៏មើលឃើញពីកង្វះខាតមួយចំនួន ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមដើម្បីឱ្យការប្រមូលអាករបំភ្លឺសាធារណៈ និងអាករពិសេសកាន់តែប្រសើឡើងដូចជា ៖

- អាជីវកម្មអាចទាញយកផលប្រយោជន៍ពីការណែនាំ ឬការបង្កើនកម្រិតអាករ ដើម្បីបង្កើនតម្លៃផលិតផល ឬសេវារបស់ខ្លួន

- ចំណូលដែលអគ្គនាយកដ្ឋានពន្ធដារបានប្រមូលមកពីអាករសម្រាប់បំភ្លឺសាធារណៈ គឺទុកសម្រាប់ចំណាយទៅលើការបំភ្លឺភ្លើងសាធារណៈនៅតាមខេត្ត-ក្រុង ប៉ុន្តែនៅតាមទីទីជនបទដាច់ស្រយាលមិនទាន់មានការបំភ្លឺភ្លើងសាធារណៈទេ
- អាករពិសេសមានបារីស្រាបៀរ និងស្រាបៀរស្ថិតក្នុងអត្រាខ្ពស់ជាងមុខទំនិញ និងសេវាផ្សេងៗដោយសារទំនិញទាំងនេះមានផលប៉ះពាល់ខ្លាំងដល់អ្នកប្រើប្រាស់
- នីតិវិធីនៃការប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ របស់អគ្គនាយកដ្ឋានពន្ធដារមិនមានភាពទូលំទូលាយដែលធ្វើឱ្យអ្នកជាប់ពន្ធមួយចំនួនមិនសប្បាយចិត្ត និងមិនសហការក្នុងភារកិច្ចនេះ ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាស្រាវជ្រាវកន្លងមកក្រុមនាងខ្ញុំសង្កេតឃើញថាការប្រមូលអាករបំភ្លឺសាធារណៈ និងអាករពិសេសកន្លងមកអាចសន្និដ្ឋានបានថាដំណើរការនៃការប្រមូលអាករទាំងពីរជាការប្រមូលពន្ធមួយប្រភេទដែរ ប្រមូលប្រាក់ចំណូលបានខ្ពស់មាន ដូចជាការកើនឡើងនៃចំនួនអ្នកជាប់ពន្ធពីមួយឆ្នាំទៅមួយឆ្នាំមានការកើនឡើងពីបុគ្គលជាប់អាករតាមរយៈការផ្គត់ផ្គង់សេវា និងទំនិញ(បារី និងសុរាមេរ័យ) ។ម្យ៉ាងវិញទៀតដំណើរការនៃការប្រមូលអាករទាំងនេះក៏ជាចលកមួយជួយជំរុញដល់ការអភិវឌ្ឍប្រទេសជាតិ និងបានចូលរួមដោះស្រាយបញ្ហាជាតិផងដែរ តាមរយៈទឹកប្រាក់ដែលប្រមូលបានត្រូវយកទៅ កសាងសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពានអាកាស ប្រាក់ខែមន្ត្រីរាជការ និងហេដ្ឋារចនាសម្ពន្ធ័នានា ។ ចំណែកមួយវិញទៀតក៏មួយទប់ស្កាត់នៃការនាំចូលទំនិញដែលប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋវាមិនត្រឹមតែជាជំហ៊ានក្នុងការបង្កើនប្រាក់ចំណូលរដ្ឋនោះទេ ប៉ុន្តែថែមទាំងមានគោលបំណងទៅលើសុខភាពសង្គម និងការរីកចម្រើនប្រកបដោយចីរភាព ។ ដោយសារតែវាសំដៅទៅលើផលិតផលដែលតម្រូវឱ្យគ្រប់គ្រងយ៉ាងម៉ត់ចត់ អាករពិសេសមានតួនាទីជាឧបករណ៍សម្រាប់ការបង្ការ និងបញ្ជូនសារទៅឱ្យសាធារណៈជនអំពីគ្រោះថ្នាក់នៃការប្រើប្រាស់សារជាតុ ឬសេវាកម្មនោះ ។ ទន្ទឹមនឹងភាពវិជ្ជាមានក្រុមដែលកើតឡើងខាងលើ តាមរយៈការស្រាវជ្រាវរបស់ក្រុមនាងខ្ញុំក៏មើលឃើញពីកង្វះខាតមួយចំនួន ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតដើម្បីឱ្យការប្រមូលពន្ធមានប្រសិទ្ធិភាពដូចជាការកំណត់កម្រិតបរិមាណនៃការនាំចូលទំនិញ និងសេវាសរុបជារួមមកយើងសង្កេតឃើញថាទោះបីមានចំណុចខ្វះខាតមួយចំនួនក៏អគ្គនាយកដ្ឋានពន្ធដារ បានខិតខំប្រឹងប្រឹងកែលម្អចំណុចខ្វះខាតទាំងនោះឱ្យកាន់តែប្រសើរឡើងថែមទៀត ។ បច្ចុប្បន្ននេះដែលអគ្គនាយកដ្ឋានពន្ធដារបានខិតខំ បណ្តុះបណ្តាលមន្ត្រីពន្ធដារ និងបន្តការកែលម្អច្បាប់ពន្ធដារឱ្យកាន់តែមានសមត្ថភាពប្រកបដោយប្រសិទ្ធិភាពបន្ថែមទៀតដើម្បីឱ្យដើរទាន់សភាពការណ៍សេដ្ឋកិច្ចដែរកំពុងតែមានការរីកចម្រើនយ៉ាងឆាប់រហ័ស ។

## ៥.២ការផ្តល់អនុសាសន៍

យោងតាមរយៈការសន្និដ្ឋានខាងលើទន្ទឹម នឹងភាពវិជ្ជមានដែលបានលើកឡើង ក្រុមរបស់នាងខ្ញុំក៏សង្កេតឃើញពីកង្វះខាតមួយចំនួន ដែលតម្រូវឱ្យមានការមានការយកចិត្តទុកដាក់បន្ថែមដើម្បីឱ្យការប្រមូលអាករបំភ្លឺសាធារណៈ និងអាករពិសេសកាន់មានការប្រសើរឡើងដូចជា ៖

- កង្វះមន្ត្រីពន្ធដារក្នុងការផ្តល់សេវាដល់អ្នកជាប់ពន្ធ ជាពិសេសនៅពេលដែលចំនួនអ្នកមកប្រកាសពន្ធមានចំនួនច្រើនពួកគេត្រូវចាំរយៈពេលយូរ ហើយមន្ត្រីទទួលលិខិតប្រកាស មិនមានពេលភ្លាមៗក្នុងការបញ្ចូលទិន្នន័យនៅក្នុងលិខិតប្រកាសទៅក្នុងប្រព័ន្ធកត់ត្រាផ្ទៃក្នុងរបស់ពន្ធដារ ដែលធ្វើឱ្យពួកគាត់អាចដឹងភ្លាមៗថាការគណនាពន្ធរបស់អ្នកជាប់ពន្ធត្រឹមត្រូវដែរឬទេ ហើយបើមានកំហុសឆ្គងក្នុងការគណនា ពេលមន្ត្រីពន្ធធ្វើការជូនដំណឹងឱ្យអ្នកជាប់ពន្ធមកធ្វើការកែតម្រូវដែលធ្វើឱ្យអ្នកជាប់ពន្ធត្រូវចំណាយពេលច្រើនក្នុងដំណើរការដាក់លិខិតប្រកាសមួយឱ្យបានត្រឹមត្រូវ ។

- អ្នកជាប់ពន្ធទៅលើអាករបំភ្លឺសាធារណៈ និងអាករពិសេសធ្វើការដាក់លិខិតប្រកាសច្រើនកុះករក្នុងកំឡុងថ្ងៃជិតផុតកំណត់ដែលជាហេតុផលធ្វើឱ្យមានការកកស្ទះខ្លាំងក្នុរយៈពេលប៉ុន្មានថ្ងៃចុងក្រោយ ។
- អ្នកជាប់អាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេសមិនទាន់យល់ច្បាស់ពីតួនាទី និងកាតព្វកិច្ចរបស់ខ្លួនក្នុងការបង់ប្រាក់ពន្ធជូនទៅពន្ធដារនៅឡើយ ដោយពួកគេគិតថាទឹកប្រាក់ដែលពួកគេបានបង់ជូនរដ្ឋមិនបានផ្តល់ផលប្រយោជន៍ដល់ពួកគេនៅថ្ងៃអនាគតបាន ។
- ដំណើរការនៃការបង់អាករសម្រាប់បំភ្លឺសារធារណៈ និងអាករពិសេសនៅមានភាពយឺតយ៉ាវនៅឡើយ ដោយសារតែប្រតិបត្តិការនៃការបង់នៅមានភាពមិនទាន់យល់ច្បាស់ពីបែបបទ និងវិធីសាស្ត្រនៃការគណនានៅឡើយ ។
- មានផលប៉ះពាល់ទៅដល់អ្នកមានប្រាក់ចំណូលទាបព្រោះការបង់អាករត្រូវបានបង់ទៅលើ ទំនិញ សេវា ភេសជ្ជៈ ស្រា បារី ដែលត្រូវបង់ជាប្រចាំ ។
- ប៉ះពាល់ដល់អាជីវកម្មក្នុងប្រទេស ជាពិសេសនៅលើផលិតផលដែលនាំចូល ។
- ការគ្រប់គ្រងពន្ធអាចមានអត្រាបង្ហាញពីប្រសិទ្ធភាពទាប ប្រសិនបើមិនមានសមត្ថភាពគ្រប់គ្រងល្អ ។

# ឯកសារយោង


១. វិទ្យាស្ថាន វ៉ាន់ដា. (២០២៤). *ច្បាប់ពន្ធដារកម្ពុជា.* បោះពុម្ពលើកទី១. ទំព័រ៣ ១០៦. ភ្នំពេញ។

២. វិទ្យាស្ថាន វ៉ាន់ដា. (២០២៤). *សេចក្តីផ្តើមនីតិ.* បោះពុម្ពលើកទី៥. ទំព័រ៣៤. ភ្នំពេញ។

៣. HOTNEWS. SEYHA. (2024, June 28). *ការដំឡើងអាករពិសេសលើបារីជាជម្រើសដ៏ល្អក្នុងការកាត់បន្ថយការប្រើប្រាស់បារីនៅកម្ពុជា*. Retrieved from https://www.hotnews-asia.com/detail/334404

៤. Trust 4 Consultant Co., Ltd. (17, July ,2019). *មេរៀនអាករបំភ្លឺសាធារណៈ*. Retrieved June, 22 2025 from https://www.facebook.com/trust4consultant/posts/pfbid029kmXYnHcVFpTmSxfJKuSVwm2r26m3diJf58yDmxJeardrz1B1gNZ72pi8NjeVuFKl?mibextid=WC7FNe

៥. អគ្គនាយកដ្ឋានពន្ធដារ. (30, March, 2020). *តើអ្វីទៅជាអាករសម្រាប់បំភ្លឺសាធារណៈ?* Retrieved from https://www.tax.gov.kh/km/content-detail/s9owI5555450852454

៦. Khmerpress. (2024, April 18). *អ្នកចែកចាយបន្ត អ្នកលក់រាយ និងសកម្មភាពអាជីវកម្មដែលផ្គត់ផ្គង់បន្ត លើផលិតផលស្រា បារី និងមិនជាប់អាករសម្រាប់បំភ្លឺសាធារណៈ*. Retrieved from https://www.google.com/imgres

Property. Sotheary. (2021, October 25). តើពន្ធនិងអាករខុសគ្នាយ៉ាងដូចម្តេច? Retrieved June, 25 2025 from https://propertyarea.asia/archives/84407

Facebook page. Social media. (2014, November 27) *សិក្សាស្វែងយល់ច្បាប់ស្តីពីពន្ធដារ.* Retrieved June, 25 2025 from https://www.facebook.com/share/p/1CBn9rxpFa/

Share.Google. (2022). *អាករលើតម្លៃបន្ថែម.* Retrieved from https://share.google/qaTbrWcH8KrtbTFOt

Facebook page. Social media. (2022, December 15). *អាករលើតម្លៃបន្ថែម.* Retrieved June, 14 2025from https://www.facebook.com/share/1CQK6d866H/?mibextid=wwXIfr

KHsearch. ពន្ធ. (2020, March 10). *តើការផ្គត់ផ្គង់ជាប់អាករសំដៅដល់អ្វីខ្លះ?* Retrieved June, 14 2025 from https://www.khsearch.com/qna/30084

Business. (2022). *អ្នកជាប់ពន្ធ*. Retrieved from https://www.business.gov.kh/business-process/tax/value-added-tax

Fresh News. (2022, July 03). *អាករលើតម្លៃបន្ថែម.* Retrieved June, 25 2025 from https://m.freshnewsasia.com/freshnewsplus/247924-2022-07-03-10-56-22.html

Facebook page. Richeng Tax and Accounting Firm. (2024, November 21). *អាករពិសេស.* Retrieved June, 27 2025 from https://www.facebook.com/share/p/1Bw2ZmoA1Q/

KHsearch. ពន្ធ. (2020, January 21). *ដូចម្តេចហៅថាអាករពិសេសលើទំនិញនិងសេវាមួយចំនួន?* Retrieved June, 27 2025 from https://www.khsearch.com/qna/28557

Business.gov. (២០២២). *អាករពិសេស.* Retrieved June, 27 2025 from https://www.business.gov.kh/business-process/tax/special-tax

Share.google. (2021, November 28). *នីតិអន្តរជាតិសម័យកណ្តាល.* Retrieved June, 30 2025 from https://share.google/DIyIB0TOpj4eDHtL

# ឧបសម្ព័ន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៥៦ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពី
## អាករសម្រាប់បំភ្លឺសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់អត្រាអាករសម្រាប់បំភ្លឺសាធារណៈ ចំពោះការផ្គត់ផ្គង់ផលិតផលសុរា មេរ័យ ឬថ្នាំជក់។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការផ្គត់ផ្គង់ផលិតផលសុរា មេរ័យ ឬថ្នាំជក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ.១០០០.....សហវ.ប្រក.១៣២៥

# ប្រកាស
## ស្តីពី
## ការលើកលែងអាករពិសេសលើផលិតផលស៊ីម៉ងត៍ក្នុងស្រុក ដោយចាត់ទុកជាបន្ទុករបស់រដ្ឋ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអត្រាពន្ធគយ អត្រាអាករពិសេស និងអត្រាអាករនាំចេញលើមុខទំនិញមួយចំនួន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងលើកលែងអាករពិសេសលើផលិតផលស៊ីម៉ងត៍ក្នុងស្រុកដោយចាត់ទុកជាបន្ទុករបស់រដ្ឋ ដើម្បីចូលរួមគាំទ្រដល់ឧស្សាហកម្មផលិតស៊ីម៉ងត៍ក្នុងស្រុក។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសហគ្រាសផលិតស៊ីម៉ងត៍ក្នុងស្រុក។

**ប្រការ៣.-**

ត្រូវចាត់ទុកជាបន្ទុករបស់រដ្ឋនូវអាករពិសេសតាមអត្រា ៥ (ប្រាំ) ភាគរយ លើផលិតផលស៊ីម៉ងត៍ក្នុងស្រុក សម្រាប់រយៈពេល ២ឆ្នាំ ចាប់ពីឆ្នាំ២០២៥ រហូតដល់ដំណាច់ឆ្នាំ២០២៦។

**ប្រការ៤.-**

សហគ្រាសផលិតស៊ីម៉ងត៍ក្នុងស្រុកទាំងអស់ត្រូវអនុវត្តនូវកាតព្វកិច្ច ដូចខាងក្រោម៖

១- ត្រូវដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែនិងប្រចាំឆ្នាំ រួមទាំងពន្ធ-អាករដែលត្រូវបានចាត់ទុកជាបន្ទុករបស់រដ្ឋ ដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធតាមអនឡាញ (e-Filing) របស់អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២- ត្រូវកាន់ កត់ត្រា និងថែរក្សាឯកសារបញ្ជិកាគណនេយ្យនិងព័ត៌មានដែលទាក់ទិននឹងសកម្មភាពអាជីវកម្ម ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។

៣- ត្រូវខិតខំបង្កើនការបណ្តុះបណ្តាល និងផ្ទេរចំណេះដឹងនិងបច្ចេកទេសទៅបុគ្គលិកក្នុងស្រុកឱ្យបានកាន់តែច្រើន និងល្អប្រសើរ ដើម្បីចូលរួមចំណែកអភិវឌ្ឍធនធានមនុស្ស។

៤- ត្រូវបំពេញកាតព្វកិច្ចចំពោះរដ្ឋឱ្យបានត្រឹមត្រូវ ដូចជា ការបង់ពន្ធ-អាករផ្សេងទៀត សួយសាររ៉ែ និងមូលនិធិបរិស្ថាននិងសង្គម ជាដើម។

៥- ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងថ្លៃដើម សមត្ថភាពផលិត ការប្រើប្រាស់វត្ថុធាតុដើម ការបណ្តុះបណ្តាល និងការផ្ទេរចំណេះដឹងនិងបច្ចេកទេសទៅបុគ្គលិកក្នុងស្រុក និងការចូលរួមកិច្ចការសង្គម។

**ប្រការ៥.-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ